អង្គការសមាគមធាងត្នោត
Sahmakum Teang Tnaut Organization · a Cambodian Urban NGO



# ការបណ្តេញចេញ សំណង់ និងបំណុល

## ២០២៣

# បញ្ជីមាតិកា

សេចក្តីសង្ខេប.........................................................................................i

ផ្នែកទី១៖ ករណីសិក្សាពី ការបណ្តេញចេញអំឡុងពេលនៃការរីករាលដាលជាសកល នៃជំងឺកូវីដ-១៩.................................................................................១

ផ្នែកទី២៖  ការបណ្តេញចេញ និងសំណង...................................................២៥

ផ្នែកទី៣៖  ការផ្លាស់ប្តូរលំនៅឋាន និងបំណុល.............................................៤០

# សេចក្តីសង្ខេប



របាយការណ៍ផ្នែកទីមួយ ផ្នែកទីពីរ និងផ្នែកទីបី បង្ហាញជារួមអំពីស្ថានភាពសំខាន់ៗនៃការបណ្តេញចេញដោយបង្ខំ សំណង និងបញ្ហាបំណុលដែលបណ្តាលមកពីការបណ្តេញចេញ នៅកម្ពុជា ដោយលាតត្រដាងពីការមិនគោរពទាំងស្រុងចំពោះច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់ជាតិ និងអនុសាសន៍របស់អង្គការសហប្រជាជាតិ។

របាយការណ៍ លេខ៤៩ បានបង្ហាញពីករណីនៃការបណ្តេញចេញចំនួន ១២ ករណីនៅទូទាំងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តតាកែវ ចន្លោះឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២២ ចំពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩។ ការសិក្សានេះក៏បញ្ជាក់ពីសារៈសំខាន់ នៃការទទួលបានលំនៅដ្ឋាន ដែលជាទីផ្តល់សុវត្ថិភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺដូចជាកូវីដ ១៩ ជាដើម។ ទោះបីជាមានការណែនាំពីរដ្ឋាភិបាលឱ្យស្នាក់នៅផ្ទះក្នុងអំឡុងពេលជំងឺរាតត្បាតក៏ដោយ ការបណ្តេញចេញបានកើតឡើងនៅតាមទីតាំងផ្សេងៗក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងរាជធានីភ្នំពេញ។ ការបណ្តេញចេញទាំងនេះត្រូវបានចាត់ទុកថាជាការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ ដូចដែលបានគូសបញ្ជាក់ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានលំនៅឋានសមរម្យ លោកស្រី ឡៃឡានី ហ្វាហា(Leilani Farha) ។ លោកស្រី ឡៃឡានី ហ្វាហា(Leilani Farha) បានសង្កត់ធ្ងន់លើផលវិបាកដែលអាចគំរាមកំហែងដល់អាយុជីវិតពីការបណ្តេញចេញក្នុងអំឡុងពេលមានជំងឺរាតត្បាតនៅក្នុងសៀវភៅណែនាំអំពីជំងឺកូវីដ ១៩។

របាយការណ៍ លេខ៥០ ធ្វើការពិនិត្យទៅលើសំណងដែលផ្តល់ដល់សហគមន៍ក្រីក្រនៅទីក្រុងភ្នំពេញដែលត្រូវបានបណ្តេញចេញចាប់ពីឆ្នាំ ២០០៦ មក។ ការស្រាវជ្រាវពីមុនដោយអង្គការសមាគមធាងត្នោត ជាពិសេសការសិក្សាក្នុងឆ្នាំ ២០២១ បានបង្ហាញពីភាពមិនជាក់លាក់នៃរបៀប ឬទំរង់នៃការផ្តល់សំណងសម្រាប់សហគមន៍ក្រីក្រ។ ការស្រាវជ្រាវបច្ចុប្បន្ននេះ ក៏បានកត់សម្គាល់នូវភាពមិនជាក់លាក់នៃវិធីសាស្ត្ររបស់អាជ្ញាធរចំពោះការផ្តល់សំណងដល់ជនត្រូវបណ្តេញចេញ ដែលអាចធ្វើឱ្យមានការរំលោភសិទ្ធិមនុស្សជាពិសេសទាក់ទងនឹងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានលំនៅដ្ឋានសមរម្យ និងសំណងគ្រប់គ្រាន់។

ជាចុងក្រោយ របាយការណ៍ លេខ៥១ គូសបញ្ជាក់អំពីកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ក្នុងការលើក

កម្ពស់សិទ្ធិមនុស្សក្នុងការមានលំនៅឋានសមរម្យ ការហាមឃាត់ការបណ្តេញចេញដោយបង្ខំ និងកំណត់ការផ្តល់កន្លែងតាំងទីលំនៅថ្មីដែលមានចែងក្នុងសិទ្ធិទទួលបានលំនៅឋានសមរម្យ។ លំនៅឋានត្រូវបានសង្កត់ធ្ងន់ថាមានសារៈសំខាន់មិនត្រឹមតែជាតម្រូវការមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សដទៃទៀតផងដែរ។ ការសិក្សានេះបង្ហាញឱ្យឃើញថា បុគ្គលដែលជួបប្រទះការបណ្តេញចេញដោយបង្ខំដោយមិនមានលំនៅឋានត្រឹមត្រូវនៅកន្លែងតាំងលំនៅថ្មីត្រូវជំពាក់បំណុល ដែលជាហេតុនាំឱ្យខ្វះស្បៀងអាហារ ពលកម្មកុមារដោយបង្ខំ និងរំខានដល់ការអប់រំ។ ការបន្តការលំបាកនៅកន្លែងតាំងលំនៅថ្មី ដោយសារតែផ្ទះសម្បែង និងសេវាសាធារណមិនគ្រប់គ្រាន់ បង្កើតវដ្តនៃបំណុលសម្រាប់ជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ។ ការសិក្សានេះជំរុញឱ្យមានចំណាត់ការយ៉ាងម៉ឺងម៉ាត់របស់អាជ្ញាធរកម្ពុជា ដើម្បីធានាថាប្រជាពលរដ្ឋគ្រប់រូបអាចដឹងពីសិទ្ធិរបស់ពួកគេក្នុងការមានលំនៅឋានសមរម្យ។

ដោយពិចារណាលើលទ្ធផលរកឃើញទាំងនេះ មានភ័ស្តុតាងបង្ហាញច្បាស់ថា ចាំបាច់ត្រូវធ្វើការកែទម្រង់ច្បាប់ និងគោលនយោបាយជាបន្ទាន់ ដើម្បីលើកកម្ពស់សិទ្ធិមានលំនៅឋានសមរម្យ ផ្តល់សំណងសមស្រប និងធានាអនុវត្តការផ្លាស់ទីលំនៅបានត្រឹមត្រូវ ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការដោះស្រាយបញ្ហាទាំងនេះ មានសារៈសំខាន់ណាស់ ក្នុងការបន្ធូរបន្ថយវិបត្តិបច្ចុប្បន្ន និងទប់ស្កាត់ការរំលោភសិទ្ធិមនុស្សជាបន្តទៀត។

ផ្នែកទី១

# ករណីសិក្សាពី៖ ការបណ្ដេញចេញអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩

## មាតិកា

១. សេចក្ដីផ្ដើម..........៣
២. វិធីសាស្ត្រ និងដែនកំណត់..........៦
៣. លទ្ធផលស្រាវជ្រាវសំខាន់ៗ..........២១
៤. សេចក្ដីសន្និដ្ឋាន..........២៣
៥. អនុសាសន៍..........២៤

# ១.សេចក្តីផ្តើម




លំនៅឋាន មានសារៈសំខាន់ណាស់សម្រាប់ប្រជាជនទូទៅ ជាពិសេសនៅអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩។ លំនៅឋានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវចេញសេចក្តីណែនាំ និងឈានដល់ការដាក់កំហិតឱ្យប្រជាប្រជាពលរដ្ឋរបស់ខ្លួននៅក្នុងផ្ទះ ព្រមទាំងមានការបិទខ្ទប់ប្រជាប្រជាពលរដ្ឋនៅតាមភូមិ សង្កាត់ រាជធានី ខេត្តដែលមានការឆ្លងខ្លាំងនៃជំងឺកូវីដ-១៩ ផងដែរ។

ផ្ទុយពីយន្តការបិទខ្ទប់ និងការណែនាំប្រជាប្រជាពលរដ្ឋឱ្យនៅតែក្នុងផ្ទះដើម្បីរក្សាគម្លាតក្នុងគោលបំណងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ នៅចន្លោះឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២២ នៅពេលដែលប្រជាជនកម្ពុជា ជាពិសេសអ្នកដែលរស់នៅក្នុងសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ និងខេត្តមួយចំនួនកំពុងប្រឈមនឹងការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩នោះ ក៏មានការបណ្តេញចេញ ដែលការបញ្ចេញចេញមួយចំនួនបានធ្វើឡើងដោយបង្ខំ និងមិនទផ្តល់សំណងសមរម្យទៅលើផលប៉ះពាល់យ៉ាងតិចចំនួន ១២ទីតាំង បានកើតឡើងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងតាកែវ។ ការបណ្តេញចេញភាគច្រើនកើតឡើងទៅលើប្រជាពលរដ្ឋ ដែលរស់នៅក្នុងសហគមន៍ក្រីក្រ ដែលមានទីតាំងនៅរាជធានីភ្នំពេញ។

ការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅឋាននៅពេលមាន ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ គឺជាការរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិមានជាអាទិ៍ សិទ្ធិមានលំនៅឋានសមរម្យ។ យោងតាមការណែនាំនៃជំងឺកូវីដ-១៩ ស្តីពីការហាមឃាត់ការបណ្តេញចេញ របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិលំនៅឋានសមរម្យនៃអង្គការសហប្រជាជាតិ ឡៃឡានី ហ្វាហា(Leilani Farha) ដែលបានចេញនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ការបណ្តេញប្រជាប្រជាពលរដ្ឋចេញពីលំនៅឋាន នៅពេលដែលលំនៅឋានជាកន្លែងដែលជួយការពារ និង

បញ្ចៀសគ្រោះថ្នាក់ដល់អាយុជីវិត ស្មើនឹងការកាត់ទោសប្រហារជីវិតប្រជាពលរដ្ឋ។[១]

## ច្បាប់ និងគតិយុត្តិទាក់ទងនឹងសិទ្ធិជាម្ចាស់កម្មសិទ្ធិ សិទ្ធិទទួលបានលំនៅឋានសមរម្យ ការបណ្តេញចេញ និងសំណង

### រដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៤៤

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ដែលនឹងដកហូតកម្មសិទ្ធិពីជនណាមួយនោះ លុះត្រាតែប្រយោជន៍សាធារណៈត្រូវបានធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

### ច្បាប់ភូមិបាលមាត្រា៣០

បុគ្គលទាំងឡាយដែលបានអាស្រ័យផលភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥(ប្រាំ) ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះ លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានកម្មសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់ បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះ ពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន។



១ អង្គការសហប្រជាជាតិ, សិទ្ធិមនុស្ស, អ្នករាយការណ៍ពិសេស៖ កំណត់សម្គាល់ការណែនាំអំពី កូវីដ -១៩ ការហាមឃាត់ការបណ្តេញចេញ អ្នករាយការណ៍ពិសេស ឡៃឡានី ហ្វាហា អ្នករាយការណ៍ពិសេសអំពីសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់, ២៨ មេសា ២០២០ , អាចរកបាននៅ៖ https://www.ohchr.org/sites/default/files/Documents/Issues/Housing/SR_housing_COVID-19_guidance_evictions.pdfhttps://www.ohchr.org/sites/default/files/Documents/Issues/Housing/SR_housing_COVID-19_guidance_evictions.pdf

## ច្បាប់អស្សាមិករណ៍មាត្រា២២

ប្រាក់សំណងដែលត្រូវផ្ដល់ឱ្យម្ចាស់អចលនវត្ថុ និង/ឬម្ចាស់កម្មសិទ្ធិ ត្រូវគិតតាមតម្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្ដីប្រកាសស្ដីអំពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍។

## ច្បាប់អស្សាមិករណ៍មាត្រា២៤

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬជាសិទ្ធិជំនួសទៅតាមភាពជាក់ស្ដែងដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬម្ចាស់កម្មសិទ្ធិ និងពីគណៈកម្មការអស្សាមិករណ៍។ បែបបទ និងនីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ២. វិធីសាស្ត្រ និងដែនកំណត់



របាយការណ៍នេះ ធ្វើឡើងតាមរយៈការសម្ភាស ជាមួយតំណាងសហគមន៍ ប្រជាសហគមន៍ និងប្រជាពលរដ្ឋដែលសហគមន៍ ឬទីតាំងលំនៅឋានរបស់ពួកគាត់បាន និងកំពុងទទួលរងការបណ្ដេញចេញចំនួន ១៧នាក់ តាមរយៈការចុះផ្សាយរបស់សារព័ត៌មានក្នុងស្រុកជុំវិញការបណ្ដេញចេញ ចាប់ពីឆ្នាំ២០១៩ ដល់២០២២ និងបណ្ដាញទំនាក់ទំនងសង្គមហ្វេសប៊ុក ដែលបានធ្វើការផ្សព្វផ្សាយជាសាធារណៈ។ ការសម្ភាសត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធទូរស័ព្ទ និងការជួបសម្ភាសផ្ទាល់។ ការស្រាវជ្រាវនេះមានលក្ខណៈគុណភាព ហើយសំណួរដែលប្រើក្នុងដំណើរការសម្ភាសគឺសំណួរបើក។ ការសម្ភាសនីមួយៗមានរយៈពេល ចន្លោះពី២៥-៤០នាទី ដែលក្រុមអ្នកស្រាវជ្រាវបានធ្វើការពន្យល់ពីវត្ថុបំណង នៃការសិក្សាស្រាវជ្រាវ និងទទួលបានការយល់ព្រមដោយផ្ទាល់មាត់ ពីអ្នកចូលរួមក្នុងបទសម្ភាសមុននឹងធ្វើការសម្ភាស។ ក្រុមអ្នកសម្ភាសក៏បាន ជូនព័ត៌មានជាមុនដល់អ្នកដែលត្រូវបានសម្ភាស អំពីការបោះពុម្ពផ្សាយខ្លឹមសារនៃកិច្ចសម្ភាស។ អត្តសញ្ញាណនិងឈ្មោះរបស់ប្រជាពលរដ្ឋដែលបានផ្ដល់ការសម្ភាសសម្រាប់របាយការណ៍នេះនឹងមិនត្រូវបានបញ្ចេញជាសាធារណៈទេ។



ការរកឃើញនៃការសិក្សានេះមិនមានលក្ខណៈជាការសិក្សាតាមបែបស្ថិតិទេ។ តួលេខនៃចំនួនគ្រួសារដែលត្រូវបានបណ្តេញចេញទាំងអស់នៅក្នុងរបាយការណ៍នេះមិនតំណាងឱ្យតួលេខនៃការបណ្តេញចេញ នៅរាជធានីភ្នំពេញ និងទូទាំងប្រទេសនៅក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ទេ។ របាយការណ៍នេះរាប់បញ្ចូលករណីនៃការបណ្តេញចេញចំនួន ១២ ដែលបានកើតឡើងក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ។ វាអាចទៅរួចដែលថា អង្គការសមាគមធាងត្នោត អាចនឹងខកខានមិនបានរាប់បញ្ចូលករណីមួយចំនួន។ ប្រសិនបើមានព័ត៌មានណាមួយមិនច្បាស់លាស់ សូមធ្វើការទំនាក់ទំនងមកកាន់ អង្គការសមាគមធាងត្នោត។



បញ្ជាក់៖ ការសិក្សានេះត្រូវបានធ្វើឡើងក្នុងខែឧសភា ដល់ខែកក្កដា ឆ្នាំ២០២២។

# ផែនទី៖ ១២ទីតាំង ដែលត្រូវបានបណ្តេញចេញអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩



# តារាង៖ ១២ទីតាំង ដែលត្រូវបានបណ្តេញចេញអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩

| ល.រ | ឈ្មោះ សហគមន៍ | មុនការបណ្តេញចេញ | ការបណ្តេញចេញ | ក្រោយការបណ្តេញចេញ |
|---|---|---|---|---|
| ១ | សហគមន៍ បន្ទាយស្លឹក | សហគមន៍បន្ទាយស្លឹកមានទីតាំងក្នុងភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ ប្រជាជនដែលរស់នៅក្នុងសហគមន៍បានមកតាំងទីលំនៅ ក្នុង១៩៩៣ និងបានចងក្រងជាសហគមន៍ នៅឆ្នាំ២០០០ ដែលមានប្រជាជនរស់នៅសរុប ចំនួន ៨៧គ្រួសារ ប្រជាជនរស់នៅទីតាំងខាងលើនេះមិនមានប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ និងមិនមានការទទួលដឹងឮពីអាជ្ញាធរមូលដ្ឋានដែរ។ ប្រជាសហគមន៍ប្រកបមុខរបរជាអាជីវករលក់ដូរ កម្មករសំណង់ កម្មករ-កម្មការីរោងចក្រ និងអ្នកទិញអេតចាយ ជាដើម។ | សហគមន៍បន្ទាយស្លឹកត្រូវបានបណ្តេញចេញនៅក្នុងឆ្នាំ២០២០។ អាជ្ញាធរមកពីសាលារាជធានីភ្នំពេញ បានចុះមកទីតាំងសហគមន៍ ក្នុងភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកងរាជធានីភ្នំពេញដោយផ្ទាល់ និងអញ្ជើញប្រជាសហគមន៍ ទៅប្រជុំនៅសាលាខណ្ឌបឹងកេងកង ហើយបានលើកឡើងនូវសំណើឱ្យប្រជាសហគមន៍ចេញពីសហគមន៍នៅឆ្នាំ២០២០។ ប្រជាពលរដ្ឋឬប្រជាសហគមន៍បន្ទាយស្លឹកយល់ព្រមចេញដោយស្ម័គ្រចិត្តជាមួយនឹងសំណងមានលុយ ១០០ដុល្លារ ដីទំហំ៤x១៥ម៉ែត្រ ផ្តល់ប្លង់កម្មសិទ្ធិ (ប្លង់ទន់) ថ្លៃដឹកជញ្ជូនអីវ៉ាន់ដល់ទីតាំងរស់នៅថ្មី និងថ្លៃជួលផ្ទះមួយខែទំរាំនឹងលំនៅឋានថ្មីសាងសង់រួច។ មូលហេតុនៃការបណ្តេញ គឺដោយសារសាលារាជធានីភ្នំពេញត្រូវការសាងសង់ផ្លូវសម្រាប់ការអភិវឌ្ឍ។ ដំណើរការនៃការបណ្តេញចេញនេះមានរយៈពេល ប្រហែលជាមួយខែ សហគមន៍បានទទួលសំណង ហើយចាកចេញនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០។ | សហគមន៍បន្ទាយស្លឹកបច្ចុប្បន្នប្តូរទីតាំងទៅភូមិវិហារសួគ៌ខាងជើង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាខេត្តកណ្តាល។ បច្ចុប្បន្នមានប្រជាជនរស់ក្នុងទីតាំងថ្មីនេះប្រមាណជា៤៥គ្រួសារ និងមានតែ៥៧ខ្នងផ្ទះប៉ុណ្ណោះបូករួមទាំងផ្ទះដែលទុកចោល។<br><br>ប្រជាសហគមន៍ខ្លះបានបាត់បង់ការងារ មុខរបរ និងបារម្ភខ្លាចមានការបណ្តេញចេញជាថ្មីម្តងទៀត។<br><br>ប្រជាសហគមន៍ខ្លះទៀតមិនទៅរស់នៅទីតាំងថ្មីនោះទេដោយសារកត្តាភូមិសាស្ត្រ ការងារ ការសិក្សារបស់កូនៗ និងជីវភាព។ |

| | | | | |
|---|---|---|---|---|
| ២ | សហគមន៍បឹងឈូកអេ និងតំបន់នៅជាប់សហគមន៍ | សហគមន៍បឹងឈូកអេ មានទីតាំងនៅភូមិបឹងឈូក សង្កាត់គីឡូលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ប្រជាជនដែលរស់នៅក្នុងសហគមន៍នេះបានមកតាំងទីលំនៅ ក្នុងឆ្នាំ១៩៩២ និងបានចងក្រងជាសហគមន៍នៅឆ្នាំ១៩៩៥ ដែលមានប្រជាជនរស់នៅសរុបចំនួន ៤៦គ្រួសារ ប្រជាជនរស់នៅទីតាំងខាងលើនេះមិនមានប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់នោះទេ ប៉ុន្តែមានការទទួលដឹងឮពីអាជ្ញាធរមូលដ្ឋាន។ ប្រជាសហគមន៍ប្រកបមុខរបរជាអាជីវករលក់ដូរ កម្មករសំណង់ កម្មករ-កម្មការីរោងចក្រ រត់ម៉ូតូឌុប រត់រ៉ឺម៉កកង់បី និងអ្នកទិញអេតចាយ ជាដើម។ | សហគមន៍បឹងឈូកអេ បាននឹងកំពុងរងការបណ្តេញចេញជាច្រើនលើកច្រើនសារ និងលើកចុងក្រោយបំផុតនៅ ខែកក្កដា ឆ្នាំ២០២១។ មុនរងការបណ្តេញចេញ សហគមន៍បានទទួលសេចក្តីជូនដំណឹងជាលិខិតលាយលក្ខណ៍អក្សរមុនរយៈពេលមួយសប្តាហ៍ ហើយនៅមិនទាន់មានភាពច្បាស់លាស់អំពីការទទួលបានសំណងចំពោះប្រជាពលរដ្ឋ និងប្រជាសហគមន៍ដែលនៅសេសសល់នៅតំបន់នោះនៅឡើយ។<br><br>ប្រជាជនដែលនៅសេសសល់រំពឹងថានឹងមានការចរចា ឬការពិភាក្សាផ្តល់សំណងត្រឹមត្រូវ និងបដិសេធដាច់ខាតចំពោះការផ្លាស់ទីលំនៅទៅតំបន់ក្រៅក្រុងដូចជា សេរិនអ៊ែនជី(7NG) ឬភ្នំប្រសិទ្ធ ដែលមានទំហំដី ៤x១៥ ម៉ែត្រ ដូចដែលអាជ្ញាធរធ្លាប់បានលើកឡើង។<br><br>មូលហេតុនៃការបណ្តេញចេញគឺអាជ្ញាធរត្រូវការទីតាំងដើម្បីអភិវឌ្ឍន៍ និងសាងសង់ផ្លូវប៉េតុង។ | ផ្ទះចំនួន៦ខ្នង ត្រូវបានរុះរើដោយអាជ្ញាធរ។ ក្រោយការរុះរើម្ចាស់ផ្ទះទាំង៦ខ្នង ត្រូវបង្ខំចិត្តប្តូរទីលំនៅថ្មីរៀងខ្លួន ជាមួយសំណង ៥០០ដុល្លាអាមេរិកតែប៉ុណ្ណោះ។ |

| | | | | |
|---|---|---|---|---|
| ៣ | ព្រលានយន្តហោះថ្មី<br><br>ឃុំជើងកើបនិងឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល | ភូមិសាស្ត្រឃុំជើងកើប និងឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ ប្រជាពលរដ្ឋដែលរស់នៅភូមិ ឃុំនេះភាគច្រើនមកតាំងទីលំនៅតាំងពីឆ្នាំ ១៩៨៦ នៅលើដីបឹងឈ្មោះបឹងតាព្រហ្ម។ ប្រជាពលរដ្ឋដែលរស់នៅឃុំជើងកើប និងឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលមានចំនួន ១០១ គ្រួសារ និងប្រកបរបរជា អាជីវករលក់ដូរ កម្មករសំណង់ កម្មករ-កម្មការីរោងចក្រ ជាដើម។ | ប្រជាប្រជាពលរដ្ឋដែលរស់នៅឃុំជើងកើប ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលបានទទួលដំណឹងពីគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះថ្មីនេះតាំងពីឆ្នាំ២០១២។ ក្រោយមក ឆ្នាំ២០២០ អាជ្ញាធរចាប់ផ្ដើមផ្សព្វផ្សាយដល់ប្រជាប្រជាពលរដ្ឋទាំងអស់ដែលប៉ះពាល់ដោយគម្រោងនេះ ឱ្យបានដឹង ដើម្បីធ្វើការដោះដូរដី។ សំណងមានពីរជម្រើសគឺ ជម្រើសទី១ ផ្ដល់ដីទំហំ៥x៣០ម៉ែត្រ ដែលមានទីតាំងនៅដីក្រហម ស្ថិតនៅក្នុងខេត្តតាកែវ ដែលមានចម្ងាយប្រហែល ២០ គីឡូម៉ែត្រ ពីទីតាំងចាស់។ ជម្រើសទី២ ស្ថិតនៅតំបន់ដដែល គ្រាន់តែឆ្ងាយពីកន្លែងចាស់បន្តិច ដោយដោះដូរដី ៥x២០ម៉ែត្រ និងសាងសង់ផ្ទះទំហំ ៥x៨ម៉ែត្រ ជូនប្រជាប្រជាពលរដ្ឋ។<br><br>ដំបូងប្រជាពលរដ្ឋមានការតវ៉ាពីសំណង និងហេដ្ឋារចនាសម្ព័ន្ធទីតាំងថ្មី ក្រោយមានការសម្របសម្រួល និងធ្វើតាមសំណូមពររបស់ប្រជាពលរដ្ឋ អាជ្ញាធរបានរៀបចំសាងសង់ប្រព័ន្ធផ្លូវភ្លើង ទឹកស្អាត ប្រព័ន្ធលូទឹកស្អុយសូឡាតាមផ្លូវចូលរហូតដល់ផ្ទះប្រជាពលរដ្ឋ និងសាងសង់ផ្ទះ។<br><br>ជាលទ្ធផល នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ប្រជាប្រជាពលរដ្ឋចំនួន ១០១គ្រួសារយល់ព្រមទទួលយកសំណង និងប្ដូរទៅទីតាំងថ្មី (ជម្រើសទី ២) ដោយស្ម័គ្រចិត្ត ។ មូលហេតុនៃការបណ្ដេញ គឺដោយសារតែសាងសង់ប្រលានយន្តហោះថ្មី។ | ប្រជាពលរដ្ឋ១០១គ្រួសារបានប្ដូរមករស់នៅទីតាំងថ្មីស្ថិតនៅក្នុងភូមិកំពុងតាឡុង ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២១។ ពួកគាត់ទទួលបាន ដីទំហំ៥x-២០ម និងផ្ទះទំហំ (៥x៨ម) មានប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ (ប្លង់រឹង)។ |

| | | | | |
|---|---|---|---|---|
| | ព្រលានយន្តហោះថ្មីឃុំបឹងខ្យាង ឃុំអំពៅព្រៃ ឃុំព្រែកស្លែង ក្នុងស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងឃុំពត់សរ ស្រុកបាទីខេត្តតាកែវ | ភូមិសាស្ត្រឃុំបឹងខ្យាង ឃុំអំពៅព្រៃ ឃុំព្រែកស្លែង ក្នុងស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងឃុំពត់សរ ស្រុកបាទីខេត្តតាកែវ។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់នៅក្នុងភូមិ ឃុំទាំងនេះមានចំនួនប្រមាណជា ៣៣០ គ្រួសារ ដែលមានទំហំដីសរុបចំនួន ១លានម៉ែត្រការ៉េ ដែលម្ចាស់ដីបានអះអាងថាមានប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ (ប្លង់រឹង)។[២] | នៅក្នុងឆ្នាំ២០១៨ ប្រជាពលរដ្ឋចាប់ផ្ដើមទទួលបានដំណឹងពីការដោះដូរដី ដើម្បីសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មី ដោយផ្ដល់សំណងជាប្រាក់ ៨ដុល្លារក្នុង១ម៉ែត្រការ៉េ។ ប្រជាពលរដ្ឋភាគច្រើនមិនយល់ព្រមទទួលសំណងដែលផ្ដល់ដោយម្ចាស់គម្រោង ព្រោះពួកគេយល់ថាសំណងមិនសមរម្យទៅនឹងការបាត់បង់របស់ពួកគេ។ ប្រជាពលរដ្ឋប្រមាណជា ៣៣០គ្រួសារ បានធ្វើការដាក់ញត្តិតវ៉ា និងមានការប៉ះទង្គិចគ្នារវាងអាជ្ញាធរ និងប្រជាប្រជាពលរដ្ឋដែលរងការប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍នេះ។ បច្ចុប្បន្នប្រជាពលរដ្ឋមួយភាគច្រើន បង្ខំចិត្តទទួលសំណង និងចាកចេញដោយសារមិនមានដំណោះស្រាយ និងប្រជាពលរដ្ឋមួយចំនួនតូចនៅបន្តការតវ៉ារបស់ពួកគេ។ | ប្រជាពលរដ្ឋដែលយល់ព្រមទទួលយកសំណងទាំងបង្ខំចិត្តបានចាកចេញ និងទៅតាំងទីលំនៅ នៅទីតាំងថ្មីផ្សេងៗគ្នា។ ប្រជាពលរដ្ឋដែលបានចាកចេញ និងបន្តចាកចេញបានបាត់បង់ដីសម្រាប់បង្កបង្កើនផល និងមានបំណុលធនាគារ។[៣]<br><br>ជាធម្មតា សម្រាប់សហគមន៍ដែលត្រូវបានបណ្ដេញចេញ តែងតែខ្ចីប្រាក់គេដើម្បីសាងសង់ផ្ទះថ្មី ជាពិសេសនៅពេលដែលសំណងមិនគ្រប់គ្រាន់។ |
| ៤ | បឹងសំរោង[៤] | ទីតាំងនេះមានប្រជាពលរដ្ឋរស់នៅចំនួន១០៨គ្រួសារ ស្ថិតនៅភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ពួកគាត់បានមកតាំងទីលំនៅតាំងពីឆ្នាំ១៩៩៦ មកម្ល៉េះ។ ប្រជាប្រជាពលរដ្ឋនៅទីតាំងនេះប្រកបរបរដូចជា នេសាទ អាជីវករលក់ដូរ កម្មករសំណង់ កម្មករ-កម្មការីរោងចក្រ ជាដើម។ | សហគមន៍នេះត្រូវបានបណ្ដេញចេញនៅឆ្នាំ ២០២១។ ខាងអាជ្ញាធរខណ្ឌបានជូនដំណឹងលាយលក្ខណ៍អក្សរ មុនជាងមួយខែ ដល់សហគមន៍។<br><br>សំណងជាគោលនយោបាយដែលអាជ្ញាធរផ្ដល់ជូនប្រជាពលរដ្ឋគឺការប្ដូរដីទំហំ ៤.២ X ១៨ ម៉ែត្រ ជាថ្នូរនឹងការចាកចេញទៅរស់នៅទីតាំងថ្មី នៅភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ។<br><br>មូលហេតុបណ្ដេញចេញ គឺដោយសារតែដីគេមានម្ចាស់ដែលគេបានទិញពីរដ្ឋ។<br><br>ប្រជាប្រជាពលរដ្ឋ ៣២គ្រួសារក្នុងចំណោម១០៨គ្រួសារបានធ្វើការបដិសេធមិនទទួលសំណងដែលផ្ដល់ដោយអាជ្ញាធរ ដោយយល់ថាសំណងមិនសមរម្យ ហើយពួកគេក៏បាន ប៉ះទង្គិចហិង្សាជាមួយអាជ្ញាធរផងដែរ។ | បច្ចុប្បន្ន ប្រជាប្រជាពលរដ្ឋដែលយល់ព្រមទទួលសំណងបានប្ដូរទៅរស់នៅទីតាំងថ្មី នៅភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ហើយមានគ្រួសារដែលរស់នៅជាក់ស្ដែងចំនួន ៦២ គ្រួសារ។ |

[២] វីអូឌី, ពលរដ្ឋមួយចំនួនដែលរងផលប៉ះពាល់ពីគម្រោងព្រលានយន្តហោះថ្មី រក្សាជំហរមិនយកសំណង៨ដុល្លារក្នុង១ម៉ែត្រការ៉េ, ០៧ វិច្ឆិកា ២០២២, អាចរកបានតាមរយៈ៖ https://www.vodkhmer.news/2022/11/07/some-citizens-affected-kandal-airport-project-remain-non-compensation/
[៣] ដូចខាងលើ
[៤] អ៊ំ អែហ្វ អាយ, បញ្ហាដីធ្លី៖ អាជ្ញាធរនិងប្រជាពលរដ្ឋបឹងសំរោងជាង៣០គ្រួសារ ប៉ះទង្គិចគ្នានៅពេលអាជ្ញាធរចុះអនុវត្តន៍នីតិវិធី, ១៥ មករា ២០២១, អាចរកបានតាមរយៈ៖ http://surl.li/ojlmy

| | | | | |
|---|---|---|---|---|
| ៥ | ផ្លូវល្បឿនលឿនទៅក្រុងព្រះសីហនុ | ភូមិសាស្ត្រភូមិចែងមែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ប្រជាប្រជាពលរដ្ឋមួយចំនួនបានតាំងទីលំនៅតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ និងបន្តមករស់នៅទីតាំងដដែលក្រោយរបបកម្ពុជាប្រជាធិបតេយ្យផុតរលត់ទៅ និងមានប្លង់កម្មសិទ្ធិស្របច្បាប់ (ប្លង់រឹង)។ | គម្រោងសាងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ អាជ្ញាធរជូនដំណឹងដល់ប្រជាប្រជាពលរដ្ឋដែលប៉ះពាល់រស់នៅភូមិចែងមែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឱ្យផ្លាស់ទីលំនៅ នៅឆ្នាំ២០២១ ក្នុងសំណងចន្លោះ៣០ ០០០ ទៅ៤០ ០០០ដុល្លាអាមេរិក ក្នុងមួយខ្នងផ្ទះ។ ប្រជាពលរដ្ឋភាគច្រើនបានបដិសេធមិនព្រមទទួលយកសំណង ដែលលើកឡើងដោយអាជ្ញាធរ ហើយរំពឹងថាអាជ្ញាធរ នឹងបន្តការចរចា ដើម្បីទទួលបានដំណោះស្រាយ ដែលអាចសមរម្យចំពោះការខូចខាតរបស់ពួកគាត់។<br><br>ខុសពីការរំពឹងទុករបស់ប្រជាប្រជាពលរដ្ឋ នៅថ្ងៃពុធ ទី២៧ ខែតុលា ឆ្នាំ២០២១ អាជ្ញាធរបានចុះរុះរើ វាយកំទេចផ្ទះជាពលរដ្ឋដោយមិនបានជូនដំណឹងជាមុន និងបង្ខំឱ្យប្រជាពលរដ្ឋផ្តិតមេដៃទទួលយកសំណងភ្លាមៗនៅនឹងកន្លែង ។<br><br>មូលហេតុនាំឱ្យមានការបណ្តេញចេញគឺ សាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ។[៥] | ប្រជាប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ទាំងស្រុងបង្ខំចិត្តទទួលយកសំណងដែលផ្តល់ដោយអាជ្ញាធរ និងចាកចេញជាមួយនិងសំណងចន្លោះពី ៣០ ០០០ ទៅ៤០ ០០០ដុល្លាអាមេរិក ឬពាក់កណ្តាលនៃតំលៃអចលនទ្រព្យដែលបាត់បង់ និងបំណុលធនាគារដែលអះអាងថាមានចំនួនច្រើនជាងសំណងដែលទទួលបាន។[៦] ប្រជាពលរដ្ឋមួយចំនួនដែលត្រូវបានបណ្តេញចេញបាត់បង់លំនៅឋាន មុខរបរប្រាក់ចំណូល និងមានវិបត្តិផ្លូវចិត្ត។ |

[៥] វីអូឌី, ពលរដ្ឋរងផលប៉ះពាល់ពីគម្រោងផ្លូវល្បឿនលឿន សោកស្តាយដែលអាជ្ញាធរកម្ទេចផ្ទះដោយផ្តល់សំណងតិចតួច, អាចរកបានតាមរយៈ៖ https://www.vodkhmer.news/2021/10/30/families-impacted-in-pp-sv-highway-project-regret-that-authorites-distroyed-their-house/
[៦] ដូចខាងលើ

| | | | | |
|---|---|---|---|---|
| ៦ | សហគមន៍ស្ទឹងកំបុត | សហគមន៍ស្ទឹងកំបុតមានទីតាំងនៅក្នុងភូមិឡូរកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ប្រជាសហគមន៍ បានមកតាំងទីលំនៅតាំងពីឆ្នាំ១៩៩០ និងចងក្រងជាសហគមន៍នៅឆ្នាំ២០០០។ សហគមន៍នេះមានប្រជាប្រជាពលរដ្ឋរស់នៅសរុបចំនួន ២៤០គ្រួសារ មិនទាន់មានប្លង់កម្មសិទ្ធិនៅឡើយ។ ប្រជាសហគមន៍ប្រកបមុខរបរជាអ្នកនេសាទ អាជីវករលក់ដូរ កម្មកសំណង់កម្មករ-កម្មការីរោងចក្រ ជាងផ្សារដែក ជាងម៉ូតូ-ឡានជាដើម។ | សហគមន៍បាន និងកំពុងរងការបណ្តេញចេញតាំងពីឆ្នាំ ២០១៩ មកម្លេះ។ កាលពីចុងឆ្នាំ២០១៩ អាជ្ញាធរបានជូនដំណឹងពីគម្រោងពង្រីកផ្លូវ ៣០ម៉ែត្រ ទៅដល់ប្រជាពលរដ្ឋដែលរស់នៅជុំវិញតំបន់នោះ ដោយគម្រោងនេះបានធ្វើឱ្យប៉ះពាល់ដល់ដីផ្ទះទាំងស្រុងរបស់ប្រជាប្រជាពលរដ្ឋខ្លះ និងខ្លះទៀតពាក់កណ្តាល ហើយ អាជ្ញាធរបានស្នើដល់ប្រជាពលរដ្ឋ ឱ្យដោះដូរទៅទីតាំងថ្មី នៅតំបន់អភិវឌ្ឍន៍ព្រែកអូរវែង ស្ថិតនៅភូមិបឹងស្រឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវវិញ ប៉ុន្តែប្រជាប្រជាពលរដ្ឋមិនព្រមទទួលយកនូវសំណើនោះទេ។ មូលហេតុនៃការបណ្តេញ គឺពង្រីកផ្លូវ៣០ម៉ែត្រ ពីផ្លូវលេខ១០០៣ តភ្ជាប់ទៅមហាវិថីឈ្នះ-ឈ្នះ។ តំណាងប្រជាប្រជាពលរដ្ឋដែលបានផ្តល់បទសម្ភាស យល់ថាសំណងមិនទាន់ សមស្របទៅនឹងតម្លៃទីផ្សារ នាពេលបច្ចុប្បន្ននោះទេ។ ប្រជាពលរដ្ឋភាគច្រើនទាមទារការអភិវឌ្ឍនៅនឹងកន្លែង និងស្នើសុំប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ ហើយការពង្រីកផ្លូវ ៣០ម៉ែត្រនោះ ស្នើសុំអាជ្ញាធរមូលដ្ឋានឱ្យកាត់ដីខាងបុរីពាក់កណ្តាលជំនួសការឱ្យប្រជាជនផ្លាស់ប្តូរទីលំនៅថ្មី។[៧] បច្ចុប្បន្នមានប្រជាសហគមន៍ចំនួន ៣៥គ្រួសារ យល់ព្រមជាមួយអាជ្ញាធរក្នុងការដោះដូរ ក្រោយប្រជាពលរដ្ឋទាំងនោះមិនរំពឹងថាអាជ្ញាធរ នឹងយល់ព្រមតាមសំណើសុំអភិវឌ្ឍន៍នៅនឹងកន្លែង<br><br>បញ្ជាក់៖ ប្រជាសហគមន៍៣៥គ្រួសារយល់ព្រមធ្វើការដោះដូរជាមួយអាជ្ញាធរ ទៅទីតាំងថ្មីដែលស្ថិតនៅតំបន់អភិវឌ្ឍន៍ប្រឡាយអូរវែង ក្នុងសង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប៉ុន្តែមិនទាន់បានទៅ | មិនមានចំលើយ |

[៧] ពលរដ្ឋជាង២០០គ្រួសារនៅខណ្ឌឫស្សីកែវទាមទារអភិវឌ្ឍន៍នៅកន្លែងនិងបណ្ណកម្មសិទ្ធិ ខណៈអាជ្ញាធរឱ្យដូរទៅទីតាំងថ្មី - វីអូឌី - បញ្ហាវិវាទដីធ្លី (vodkhmer.news)

| | | | | |
|---|---|---|---|---|
| ៧ | បឹងតាមោក(ទីតាំងទី១) | បឹងតាមោក(ទីតាំងទី១)ស្ថិតនៅក្នុងភូមិកោះរងៀង សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ ប្រជាពលរដ្ឋបានមកតាំងទីលំនៅទីតាំងនេះ នៅចន្លោះឆ្នាំ ១៩៨៥-១៩៩០ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន២៣គ្រួសារ និងមិនទាន់មានប្លង់កម្មសិទ្ធិកាន់កាប់ដីស្របច្បាប់។ ប្រជាពលរដ្ឋនៅទីតាំងនេះប្រកបមុខរបរជាកម្មករសំណង់ កម្មករ-កម្មការិនីរោងចក្រ អ្នកលក់ដូរ អ្នកនេសាទ ស៊ីឈ្នួលគេជាដើម។ | ប្រជាពលរដ្ឋនៅទីតាំងនេះ ត្រូវបានបណ្តេញចេញនៅរវាងឆ្នាំ ២០២១ និង២០២២។ មូលហេតុនៃការបណ្តេញចេញ យកដីអភិវឌ្ឍន៍ធ្វើផ្សារដើមគរ ប៉ុន្តែបច្ចុប្បន្នទីតាំងដីនេះក្លាយជាដីកម្មសិទ្ធិឯកជន។ បើតាមប្រជាសហគមន៍ការបណ្តេញចេញនេះមិនទទួលបានការជូនដំណឹងពីការបណ្តេញចេញជាមុនទេ។ អាជ្ញាធរធ្វើការគំរាមកំហែង រុះរើកំទេចផ្ទះប្រជាពលរដ្ឋ ដោយមិនមានជូនដំណឹង និងយល់ព្រមពីប្រជាពលរដ្ឋជាច្រើនលើកច្រើនសារ។ អាជ្ញាធរចោទប្រកាន់ថារស់នៅលើដីរដ្ឋដោយ មិនស្របច្បាប់ និងអនាធិបតេយ្យ។ ក្រោយពីមានការតវ៉ា និងចរចាពីសំណាង សមាជិកសហគមន៍ចំនួន១៣គ្រួសារយល់ព្រមចាកចេញដោយស្ម័គ្រចិត្ត ជាមួយសំណង ជាប្រាក់ចំនួន ៥០០ ដុល្លារ និងដី ៥x១៨ម៉ែត្រ និងប្លង់កម្មសិទ្ធិដឹងឮ ត្រឹមភូមិ-ឃុំ (ប្លង់ទន់) នៅទីតាំងថ្មីភូមិទួល សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញនៅខែ ធ្នូ ឆ្នាំ២០២១។<br><br>គ្រួសារចំនួន១០ គ្រួសារដែលនៅបន្តតវ៉ា និងចរចាជាមួយអាជ្ញាធរសម្រេចចិត្តចាកចេញទៅទីតាំងថ្មីភូមិស្រែដូនតូច សង្កាត់ពញ៉ាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នៅប្រហែលចន្លោះខែឧសភា ឆ្នាំ២០២២ ជាមួយសំណងជាប្រាក់ចំនួន ១៣០០០ ដុល្លាអាមេរិក ដីទំហំចន្លោះពី៥x២៥ម៉ែត្រ ទៅ៥x៣០ ម៉ែត្រ និងផ្ទះទំហំ ៥x១២ម៉ែត្រ (ធ្វើឱ្យ៥០%) ប៉ុន្តែមិនទាន់ទទួលបានប្លង់កម្មសិទ្ធិ។ | ប្រជាពលរដ្ឋ១៣គ្រួសារដែលទៅរស់នៅទីតាំងថ្មីនៅភូមិទួល សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ ទទួលបានការរៀបចំប្រព័ន្ធផ្លូវបេតុង ទឹកភ្លើង និងប្រព័ន្ធលូរួចជាស្រេច។ ប្រជាពលរដ្ឋបាត់បង់ចំណូល និងត្រីដែលជាម្ហូបទទួលទានប្រចាំថ្ងៃដែលទទួលបានពីការប្រកបមុខរបររកត្រីនៅទីតាំងចាស់ ជំពាក់បំណុលធនាគារ ពិបាកក្នុងការប្រកបមុខរបរនៅក្នុងសហគមន៍ព្រោះសហគមន៍មានទំហំតូច និងមនុស្សតិចជាងមុន ពិបាករកការងារថ្មី និងឆ្ងាយពីកន្លែងធ្វើការចាស់ និងព្រួយបារម្ភខ្លាចមានការបណ្តេញចេញបន្តទៀត (បានប្លង់ទន់នៅឡើយ)។<br><br>ប្រជាប្រជាពលរដ្ឋ១០ គ្រួសារទៀតដែលទៅរស់នៅទីតាំងថ្មីនៅភូមិស្រែដូនតូច សង្កាត់ពញ៉ាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញដែលមានការរៀបចំប្រព័ន្ធផ្លូវបេតុង ទឹកភ្លើង និងប្រព័ន្ធលូរួចជាស្រេចហើយ។ ប្រជាប្រជាពលរដ្ឋទាំង១០ គ្រួសារនេះប្រឈមនឹងបញ្ហាស្រដៀងគ្នានឹងប្រជាប្រជាពលរដ្ឋ ១៣គ្រួសារទៀត រួមទាំងទទួលរងបណ្តឹងទៅតុលា ដោយសារជំលោះទាក់ទងបញ្ហាដីធ្លីនៅទីតាំងចាស់។ |

| | | | | |
|---|---|---|---|---|
| ៨ | បឹងតាមោក(ទីតាំងទី២) | បឹងតាមោក(ទីតាំងទី២) មានទីតាំងភូមិកប់ស្រូវ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ ប្រជាពលរដ្ឋនៅទីតាំងមានចំនួន៨៨គ្រួសារ[៨] បានចូលទៅអាស្រ័យផលតាំងពីឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ប្រជាពលរដ្ឋនៅទីតាំងនេះភាគច្រើន ប្រកបរបរជាអ្នកនេសាទត្រី និងធ្វើកសិកម្ម ដោយធ្វើស្រែប្រាំង ដាំឈូក ដាំបន្លែបង្ការផ្សេងៗ។[៩] | នៅចុងឆ្នាំ២០២១ ដី៧៩ហិកតា របស់អ្នកភូមិ ៨៨គ្រួសារ ដែលនៅជាប់បឹងកប់ស្រូវ ឬបឹងតាមោក ស្ថិតក្នុងភូមិកប់ស្រូវ សង្កាត់គោករកា មានសកម្មភាពចាក់ដីលុប ដោយមិនមានដំណោះស្រាយផលប៉ះពាល់ឡើយ។[១០]<br><br>តំណាងប្រពលរដ្ឋបាន ឱ្យដឹងថា កន្លងមក អ្នកភូមិធ្លាប់រកកិច្ចអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានឱ្យជួយដោះស្រាយដែរ ប៉ុន្តែអាជ្ញាធរពុំមានចំណាត់ការណាមួយឡើយ ទើបពួកគាត់នាំគ្នាមកតវ៉ានៅសាលាសង្កាត់គោករកាម្តង ហើយម្តងទៀត ដើម្បីស្វែងរដំណោះស្រាយ។ ប្រជាពលរដ្ឋស្នើឱ្យអាជ្ញាធរដោះស្រាយឱ្យបានសមរម្យ ខណៈដីនៅទីតាំងខាងលើត្រូវបានពួកគាត់ចូលកាន់កាប់អាស្រ័យផលជាង៣០ឆ្នាំកន្លងមកហើយ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យផ្តល់ជូនដីដែលមានទីតាំងខាងលើនេះទៅក្រសួងមួយចំនួន ដើម្បីសាងសង់និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ | ប្រជាពលរដ្ឋដែលបានរងការបណ្តេញចេញបានបាត់បង់ដីដែលខ្លួនធ្លាប់កាន់កាប់ ហើយពុំមានដីសម្រាប់បង្កបង្កើនផល ដើម្បីចិញ្ចឹមជីវិតដូចមុនទៀតឡើយ។[១១] |

[៨] វីអូឌី, ពលរដ្ឋនៅជាប់បឹងតាមោកតវ៉ាមុខសាលាសង្កាត់គោករកា ទាមទារឱ្យមានដំណោះស្រាយរឿងដីធ្លី, ២១ មីនា ២០២២, អាចរកបានតាមរយៈ៖ https://www.vodkhmer.news/2022/03/21/residents-protest-at-prek-pnov-district-demanding-land-settlement-of-ta-mok-lake/

[៩] វីអូឌី, ពលរដ្ឋ៨០គ្រួសារនៅជាប់បឹងតាមោកចោទក្រុមហ៊ុនឯកជនមួយថារំលោភយកដីរបស់ពួកគេ, ២៥ កុម្ភៈ ២០២២, អាចរកបានតាមរយៈ៖ https://www.vodkhmer.news/2022/02/25/families-near-ta-mok-lake-accuse-a-private-company-of-encroaching-on-their-land/

[១០] ដូចខាងលើ

[១១] ដូចទី៨

| | | | | |
|---|---|---|---|---|
| ៩ | ផ្លូវរថភ្លើង | សហគមន៍ផ្លូវរថភ្លើងមានទីតាំងនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានតាំងទីលំនៅនៅក្នុងឆ្នាំ១៩៩៣ និងបានចងក្រងជាសហគមន៍នៅឆ្នាំ២០១០ សហគមន៍មិនទាន់មានប្លង់កម្មសិទ្ធស្របច្បាប់នៅឡើយទេ។ សហគមន៍មានគ្រួសារដែលរស់នៅជាក់ស្តែងចំនួន ៨៣ គ្រួសារ។ ប្រជាសហគមន៍នេះមានមុខរបរដូចជា ជាមន្ត្រីរាជការអ្នករត់ម៉ូតូឌុប អាជីវករលក់ដូរ កម្មករសំណង់ កម្មករ-កម្មការីរោងចក្រជាដើម។ | សហគមន៍នេះទទួលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ផ្លូវរបស់ធនាគារពិភពលោកតាំង ពីឆ្នាំ ២០០៩ មកម្លេះ។ នៅឆ្នាំ២០១៨ និង ២០១៩ ខាងសាលាក្រុងបានធ្វើការជូនដំណឹង ជាលាយលក្ខណ៍អក្សរ រយៈពេល១៥ថ្ងៃ និងចរចារជាមួយសហគមន៍ពីការប្តូរទីលំនៅពីទីតាំងចាស់នៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ ទៅទីតាំងថ្មីដែលស្ថិតនៅក្រោយវត្តទួលអស់លោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។<br><br>នៅចុងឆ្នាំ២០២២នេះ ប្រជាសហគមន៍បានប្តូរទៅតាំងទីលំនៅនៅទីតាំងថ្មីដោយគ្រួសារនីមួយទទួលបានដីទំហំ ៤x១៥ ម៉ែត្រ និងគ្មានសំណងបន្ថែមជាប្រាក់តាមការចង់បានរបស់ប្រជាសហគមន៍ឡើយ។ ប្រជាសហគមន៍គិតថាការបណ្តេញចេញនេះគឺជាការបណ្តេញចេញដោយបង្ខំដែលផ្ទុយពីការចង់បានរបស់ពួកគាត់ រីឯសំណងទៀតសោតក៏មិនបានសមរម្យ និងសមស្របទៅនឹងការបាត់បង់។ | ប្រជាសហគមន៍បានប្តូរទៅទីតាំងថ្មីដែលស្ថិតនៅក្រោយវត្តទួលអស់លោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ប្រជាសហគមន៍បាន និងកំពុងប្រឈមវិបត្តិមួយចំនួនដូចជា មិនទាន់មានទឹកភ្លើង ក្មេងៗពិបាកទៅសាលា មិនមានផ្លូវស្អាត និងផ្លូវបានខូចដោយមានភ្លៀងនិងការចាក់បំពេញមិនទាន់ហើយត្រឹមត្រូវ បាត់បង់ការងារ មិនមានកន្លែងស្នាក់នៅត្រឹមត្រូវដោយសារផ្ទះមិនទាន់បានសាងសង់ហើយរួចរាល់។ |

| | | | | |
|---|---|---|---|---|
| ១០ | ទួលសង្កែអេ | សហគមន៍ទួលសង្កែអេ ស្ថិតនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ បានតាំងទីលំនៅក្នុងឆ្នាំ១៩៨៥ និងបានចងក្រងជាសហគមន៍នៅឆ្នាំ១៩៩៤ សហគមន៍មិនទាន់មានប្លង់កម្មសិទ្ធិស្របច្បាប់នៅឡើយទេ។ សហគមន៍មានគ្រួសារដែលរស់នៅ ចំនួន ៨៥ គ្រួសារ។ ប្រជាសហគមន៍នេះប្រកបមុខរបរជាអ្នកនេសាទ អាជីវករលក់ដូរ កម្មករសំណង់ កម្មករ-កម្មការីរោងចក្រ និងអ្នកធ្វើការផ្នែកសេវាកម្ម ជាដើម។ | សហគមន៍ទួលសង្កែអេ ត្រូវបានទទួលរងការបណ្តេញចេញចំនួនពីរដង។ លើកទី១ សមាជិកសហគមន៍ទទួលបានការជូនដំណឹងឲ្យចាកចេញពីលំនៅឋានហើយត្រូវបានផ្តល់ដីទំហំ ៧x១៥ ម៉ែត្រការ៉េ និងប្រាក់ ចំនួន ៥០០ ដុល្លារ នៅភូមិត្រពាំងអញ្ចាញ ក្នុងខេត្តកណ្តាល កាលពីខែវិច្ឆិកា ឆ្នាំ២០១០។<br><br>សហគមន៍បានទទួលដំណឹងពីការបណ្តេញចេញលើកទី២នៅខែ សីហា ២០២២។ បន្ទាប់ពីទទួលដំណឹងពីអាជ្ញាធរ ពីការបណ្តេញចេញឱ្យទៅរស់នៅទីតាំងថ្មី សហគមន៍បានយល់ព្រមស្ម័គ្រចិត្តចេញមកទីតាំងថ្មីដោយមិនមានការតវ៉ា។ មូលហេតុដែលបណ្តាលឱ្យមានការបណ្តេញចេញ គឺសាងសង់ផ្លូវប៉េតុង នៅលើធ្វើផ្លូវរថភ្លើង ពីបឹងកក់ទៅព្រែកលាប។ សហគមន៍ទទួលបានសំណងជាដីទំហំ ៤x១៥ ម៉ែត្រ។ | តំបន់តាំងទីលំឋានថ្មី នៅភូមិក្រោលគោ ស្ថិតក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កំពុងប្រឈមនឹងបញ្ហាជាច្រើន។ ថ្វីត្បិតតែភូមិសាស្ត្រនេះមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏នៅតែមានលំនៅឋានជាច្រើនដែលមិនមានទឹក និងភ្លើងជាដើម។ កង្វះឱកាសការងារ និងការធ្វើដំណើរឆ្ងាយទៅសាលារៀន ធ្វើឱ្យកុមារមានផលលំបាកក្នុងការទទួលបានការអប់រំ។ |

| | | | | |
|---|---|---|---|---|
| ១១ | ផ្លូវជាតិលេខ៥ | ទីតាំងភូមិសាមគ្គី សង្កាត់ឫស្សីកែវ និងភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ប្រជាពលរដ្ឋចាប់ផ្ដើមមកតាំងទីលំនៅនៅក្នុងភូមិសាស្ត្រនេះតាំងពីឆ្នាំ១៩៨០ ដែលគិតមកដល់បច្ចុប្បន្ន ប្រជាពលរដ្ឋបានមកតាំងទីលំនៅនៅទីតាំងនេះ ចន្លោះពី១០ទៅ៣០ឆ្នាំ ប្រជាពលរដ្ឋទាំងអស់រស់នៅទីតាំងនេះមិនមានប្លង់កម្មសិទ្ធិកាន់កាប់ស្របច្បាប់។[១២] ប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរជា លក់ដូរតាមដងផ្លូវ ជាងឡានកម្មករសំណង់ និងពេងចក្រជាដើម។ | បណ្ដេញចេញនៅឆ្នាំ២០២១ និង២០២២ ដោយអាជ្ញាធរខណ្ឌឫស្សីកែវ ស្នើដល់ប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេឱ្យចាកចេញដោយសំណងផ្សេងៗគ្នា។ ការបណ្ដេញចេញ និងការផ្ដល់សំណងនេះធ្វើឡើងដោយមានការជូនដំណឹងពីការបណ្ដេញចេញពីអាជ្ញាធរខណ្ឌឫស្សីកែវ ប៉ុន្តែប្រជាពលរដ្ឋដែលជាអ្នកផ្ដល់បទសម្ភាសដល់របាយការណ៍មិនដឹងពីរយៈពេលនៃដំណើរការនៃការបណ្ដេញចេញទាំងមូលនោះទេ ហើយបញ្ជាក់ថាការបណ្ដេញចេញធ្វើឡើងដោយការជូនដំណឹងតែមិនមានជាលាយលក្ខណ៍អក្សរទេ។ ចំពោះប្រជាពលរដ្ឋដែលរស់នៅជួលដីពីគេបន្តទទួលបានសំណងប្រហែល ៧០០ដុល្លាអាមេរិកក្នុងមួយខ្នងផ្ទះ ដោយឡែកប្រជាពលរដ្ឋដែលជាម្ចាស់ដីមួយចំនួនទទួលសំណង ចន្លោះពីប្រហែលជា ៣ ០០០ដុល្លាអាមេរិកសម្រាប់ទំហំផ្ទះនិងដី៤x៤ម៉ែត្រក្រឡា ឬជាប្រាក់ចំនួនចន្លោះពី ៣០០-៣២០ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការ៉េ។ ។ ប្រជាពលរដ្ឋដែលរស់នៅទីតាំង នេះភាគច្រើនមិនចង់ចាកចេញ ឬទទួលយកសំណងដែលផ្ដល់ឱ្យដោយអាជ្ញាធរខណ្ឌឫស្សីកែវទេតែដោយគ្មានជម្រើសពួកគេត្រូវបង្ខំចិត្តចាកចេញ។[១៣] | ប្រជាពលរដ្ឋទទួលសំណង រួចចាកចេញ ទៅតាំងទីលំនៅថ្មីរៀងៗខ្លួន។ ប្រជាពលរដ្ឋបាត់បង់លំនៅឋាន និងមុខរបរប្រចាំថ្ងៃ។ |

[១២] វីអូឌី, ពលរដ្ឋរស់នៅតាមបណ្ដោយប្រាំងទន្លេក្នុងខណ្ឌឫស្សីកែវ ចង់បានសំណងសមរម្យមុនចាកចេញ, ២២ កក្កដា ២០២២, អាចរកបានតាមរយៈ៖ https://www.vodkhmer.news/2022/07/22/russey-keo-residents-want-fair-compensation-before-leaving/
[១៣] ដូចខាងលើ

| | | | | |
|---|---|---|---|---|
| ១២ | សំរោងត្បូង | សហគមន៍សំរោងត្បូងបានតាំងទីលំនៅនៅភូមិសំរោងត្បូង សង្កាត់សំរោងត្បូង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ក្នុងឆ្នាំ ១៩៩០។ សហគមន៍នេះមានប្រជាជនរស់នៅសរុបចំនួន ១០៨ ខ្នងផ្ទះស្មើនឹង ២៥០គ្រួសារ ហើយបានចងក្រងជាសហគមន៍ឱ្យឈ្មោះថាសំរោងត្បូង ដើម្បីធ្វើការដាក់ញត្តិដើម្បីស្វែងរកដំណោះស្រាយ និងប្រឆាំងតវ៉ាការបណ្តេញចេញដោយបង្ខំពីសំណាកអាជ្ញាធរខណ្ឌព្រែកព្នៅ។ រហូតមកទល់បច្ចុប្បន្នសហគមន៍នេះនៅមិនទាន់ទទួលបានប្លង់កម្មសិទ្ធិកាន់កាប់ដីដែលពួកគាត់រស់នៅ និងអាស្រ័យផលនៅឡើយទេ។ ប្រជាសហគមន៍ប្រមាណជាង៨០ភាគរយ ពឹងពាក់អាស្រ័យផលលើបឹងតាមោក ឬបឹងកប់ស្រូវដោយប្រកបរបរកសិកម្ម ដូចជាធ្វើស្រែប្រាំង ចិញ្ចឹមត្រី និងនេសាទជាដើម ក្រៅពីនេះប្រជាសហគមន៍ចំនួនតូចប្រកបមុខរបរជា កម្មករ-កម្មការិនីរោងចក្រ បុគ្គលិកក្រុមហ៊ុនឯកជន និងអាជីវករលក់ដូរជាដើម។ | នៅឆ្នាំ២០១៩ អាជ្ញាធរខណ្ឌព្រែកព្នៅបានជូនដំណឹងអំពីការបណ្តេញចេញ ដោយឱ្យប្រជាសហគមន៍ធ្វើការប្តូរទីលំនៅទីរស់នៅទីតាំងថ្មីដែលអាជ្ញានឹងរៀបចំផ្តល់ឱ្យក្នុងទំហំដី៤,៥ x១៤ម៉ែត្រ ដោយមូលហេតុប្រជាពលរដ្ឋទាំងនោះរស់នៅលើចំណីផ្លូវលេខ១៥១ ដោយខុសច្បាប់ ដែលផ្លូវនេះ រដ្ឋាភិបាលគ្រោងពង្រីកឱ្យបាន៥០ម៉ែត្រ។ ការបណ្តេញចេញនេះមិនបានធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋជាលាយលក្ខណ៍អក្សរទេ។ ប្រជាពលរដ្ឋភាគច្រើនសំណូមពរអោយមានការអភិវឌ្ឍន៍នៅនឹងកន្លែង និងផ្តល់ឯកសារសាធារណៈ ដូចជា សៀវភៅគ្រួសារ និងបណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីជាដើម ដោយមិនព្រមដោះដូរទៅកន្លែងថ្មី ដោយបារម្ភពីការបាត់បង់មុខរបរ និងមានបញ្ហាជីវភាពគ្រួសារ។<br><br>នៅក្នុងដំណើរនៃការបណ្តេញចេញនេះអាជ្ញាធរខណ្ឌព្រែកព្នៅបានចុះរុះរើស៊ងចិញ្ចឹមត្រីរបស់ប្រជាពលរដ្ឋអស់ប្រហែលជា៣០ទៅ៤០កន្លែង ព្រមទាំងមានការប្រើហិង្សា ប្តឹងតំណាងប្រជាពលរដ្ឋ៧នាក់ ទៅតុលាការក្រោមបទចោទ «រារាំងញុះញង់ និងបង្កើតសកម្មភាពអនាធិបតេយ្យ តាមដងផ្លូវសាធារណៈ» ទៅតាមបណ្តឹងរបស់លោក មាស សម្បូរ ប្រធានសន្តិសុខខណ្ឌព្រែកព្នៅក្រោយប្រជាពលរដ្ឋទាំងនេះ នាំគ្នាដើរតវ៉ាពីបញ្ហាដីធ្លីដីធ្លីរបស់ពួកគេ។[១៤] ប្រជាពលរដ្ឋបានឱ្យដឹងថា ការរុះរើកន្លែងចិញ្ចឹមត្រីរបស់ប្រជាប្រជាពលរដ្ឋនេះបានធ្វើឱ្យប្រជាពលរដ្ឋខាតបង់ផលប្រយោជន៍ជាច្រើន ដូចជា សម្ភារៈចិញ្ចឹមត្រី ថវិកា និងផលត្រី ជាដើម។ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ មានការប៉ះទង្គិចមួយផ្សេងទៀត រវាងអាជ្ញាធរ និងប្រជាពលរដ្ឋ ដែលក្នុងការប៉ះទង្គិចនោះបណ្តាលអោយស្ត្រីជាអ្នកតវ៉ាចំនួន៤នាក់រងរបួសធ្ងន់ និងស្រាសផងដែរ។ | បច្ចុប្បន្នមានប្រជាពលរដ្ឋចំនួន ២៦ខ្នងផ្ទះបានយល់ព្រមទទួលយកសំណង ឬការដោះដូរពីអាជ្ញាធររួចចាកចេញទៅរស់នៅទីតាំងថ្មី។ កញ្ចប់សំណងរួមមាន ទឹកប្រាក់ចំនួន១០០០០ ដុល្លារអាមេរិក ដីទំហំ៤,៥x១៨ ម៉ែត្រ និងផ្ទះថ្មំមួយ។ |

[១៤] វីអូឌី, ពលរដ្ឋបឹងតាមោកបោះតង់យាមមិនឱ្យអាជ្ញាធរចាក់ដីលុបកន្លែងអាស្រ័យផល ខណៈវិវាទដីធ្លីមិនទាន់ដោះស្រាយចប់, ០៨ វិច្ឆិកា ២០២២, អាចរកបានតាមរយៈ៖ https://www.vodkhmer.news/2022/11/08/boeung-ta-mok-residents-set-tents-prevent-authorities-dumping-land-enjoying/

# ៣. លទ្ធផលស្រាវជ្រាវសំខាន់ៗ



» ចន្លោះឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ស្របពេលដែលមានការការរីករាលដាលសកល នៃជំងឺកូវីដ-១៩ មានករណីបណ្តេញចេញចំនួន១២ករណីនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងតាកែវ ដែលការបណ្តេញចេញទាំងនោះមិនបានប្រព្រឹតទៅឱ្យបានត្រឹមត្រូវតាមសេចក្តីអធិប្បាយរបស់អង្គការសហប្រជាជាតិ ជុំវិញគោលការណ៍ណែនាំ ស្តីអំពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងតាមនិតិវិធីនៃច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

» ការបណ្តេញចេញនីមួយៗមានទម្រង់ខុសៗគ្នាត្រង់រយៈពេលនៃការជូនដំណឹង និងការទទួលបានសំណង ដែលមិនមានទម្រង់មួយជាក់លាក់។

» ប្រជាពលរដ្ឋដែលបានបណ្តេញចេញទៅកាន់ទីតាំងថ្មីបាត់បង់ការងារ និងមុខរបរ ការសិក្សាពិបាករកការងារថ្មីធ្វើ បារម្ភពីការបណ្តេញចេញនៅពេលអនាគតខណៈប្រជាពលរដ្ឋទាំងនោះមិនទាន់ទទួលបានលិខិតកាន់កាប់ដីស្របច្បាប់នៅទីតាំងថ្មីដែលពួកគេកំពុងរស់នៅនៅឡើយ។

» ប្រជាពលរដ្ឋដែលកំពុងរងនូវការបណ្តេញចេញកំពុងប្រឈមនឹងការបាត់បង់ការងារ និងមុខរបរ និងបាត់បង់មុខរបរបណ្តើរ ប្រាក់ចំណូលប្រចាំថ្ងៃឬសេដ្ឋកិច្ចគ្រួសារមានការធ្លាក់ចុះ ដោយសារការចំណាយពេលនិងធនធាន ធ្វើការតវ៉ា និងតស៊ូមតិ នៅពេលនការបណ្តេញចេញ។

» ប្រជាពលរដ្ឋនៅសហគមន៍ដែលកំពុងរងនូវការបណ្តេញចេញ ព្រួយបារម្ភពីភាពមិនច្បាស់លាស់នៃដំណោះស្រាយសំណងការបាត់បង់ផ្ទះសម្បែង ការគ្មានមុខរបរចិញ្ចឹមជីវិត ការទទួលបានសំណងមិនសមស្របនិងដី និងផ្ទះដែលនឹងត្រូវបាត់បង់ បារម្ភខ្លាចមានហិង្សារវាងអាជ្ញាធរ និងប្រជាប្រជាពលរដ្ឋ បារម្ភខ្លាចមានការរុះរើលំនៅឋានដោយហិង្សាដោយគ្មានការជូនដំណឹងទុកជាមុន និងការគំរាមកំហែងឱ្យពួកគេចាកចេញរបស់អាជ្ញាធរមូលដ្ឋាន។

» ប្រជាពលរដ្ឋនៅសហគមន៍ដែលកំពុងរងនូវការបណ្តេញចេញ ព្រួយបារម្ភពីការបាត់បង់ភាពងាយស្រួល ក្នុងការប្រើប្រាស់ នឹងទទួលបានសេវាសាធារណៈ ដូចជាមន្ទីរពេទ្យ

មណ្ឌលសុខភាព សាលារៀន ផ្សារម្ហូប និងការទទួលបានភាពងាយស្រួលនៃកន្លែងកំសាន្ត និងសួនច្បារសាធារណៈនានា។

» ប្រជាពលរដ្ឋនៅក្នុងសហគមន៍ដែលបណ្តេញចេញក្នុងអំឡុងពេលមានការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ទាំងអស់សុទ្ធតែបង្ហាញពីបញ្ហាវិប្បត្តិផ្លូវចិត្ត ដែលទទួលបានពីបទពិសោធន៍នៃការប៉ះទង្គិចដោយហិង្សា ការប្តឹងចោទពីបទព្រហ្មទណ្ឌដូចជាចោទប្រកាន់ពីបទហិង្សាដោយចេតនា និងមានស្ថានទម្ងន់ទោសញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងប្រឆាំងនឹងអ្នករាជការសាធារណៈដោយមានស្ថានទម្ងន់ទោស និងគំរាមកំហែង ការបាត់បង់ការងារ មុខរបរ ផ្ទះសម្បែង និងដីធ្លីជាដើម។

» ប្រជាពលរដ្ឋដែលរងការបណ្តេញចេញភាគច្រើនត្រូវបានបង្ខំឱ្យទទួលសំណងជាការផ្លាស់ប្តូរទីលំនៅថ្មី ឬប្តូរដី ឬជាចំនួនទឹកប្រាក់ណាមួយដែលមិនសមស្របតាមតម្រូវការរបស់ប្រជាប្រជាពលរដ្ឋ។



# ៤. សេចក្តីសន្និដ្ឋាន



ផ្ទុយពីការណែនាំនៃជំងឺកូវីដ-១៩ ស្តីពីការហាមឃាត់ការបណ្តេញចេញ របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិលំនៅឋានសមរម្យនៃអង្គការសហប្រជាជាតិ លីឡានី ហ្វាហា (Leilani Farha) ដែលបានចេញនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ នៅអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ មានការបណ្តេញចេញដោយបង្ខំយ៉ាងហោចណាស់ចំនួន១២ ទីតាំងក្នុងចន្លោះឆ្នាំ២០១៩ដល់ឆ្នាំ២០២២។ ដំណើរនៃការបណ្តេញចេញនីមួយៗនៅតែមិនទាន់បានប្រព្រឹត្តអនុលោមទៅតាមច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ទាក់ទងនឹងសិទ្ធិទទួលបានលំនៅឋានសមរម្យ និងគោលការណ៍ណែនាំ ស្តីអំពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅឡើយទេ ដោយភាគច្រើននៃការបណ្តេញចេញទាំងនោះធ្វើឡើងដោយបង្ខំ និងធ្វើឱ្យប៉ះដល់ជីវភាព និងអារម្មណ៍របស់ប្រជាពលរដ្ឋដែលទទួលរង និងកំពុងទទួលរងការបណ្តេញចេញ។ ប្រជាពលរដ្ឋដែលរងការបណ្តេញចេញបាត់បង់លំនៅឋាន ការងារ មុខរបរ ការធ្លាក់ចុះនៃចំណូល ការសិក្សា ភាពងាយស្រួលក្នុងការទទួលបានសេវាសាធារណៈ និងការកំសាន្តនានា រួមទាំងមានវិបត្តផ្លូវចិត្តដោយសារដំណើរការនៃការបណ្តេញចេញ និងសំណង។

# ៥. អនុសាសន៍



## រាជរដ្ឋាភិបាលកម្ពុជា

- ផ្តល់នូវកម្មសិទ្ធិដីឱ្យប្រជាពលរដ្ឋដែលកំពុងមានជំលោះបញ្ហាដីធ្លីនៅតំបន់ជុំវិញបឹងតាមោក។
- ផ្តល់សម្បទានដីដល់សហគមន៍ក្រីក្រដែលងាយរងគ្រោះ ដូចដែលបានផ្តល់ដល់បុគ្គលឯកជនមួយចំនួន ដើម្បីធានាបាននូវសិទ្ធិទទួលបានលំនៅឋានសមរម្យ។
- អនុវត្តតាមការណែនាំនៃជំងឺកូវីដ-១៩ ស្តីពីការហាមឃាត់ការបណ្តេញចេញ របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិលំនៅឋានសមរម្យនៃអង្គការសហប្រជាជាតិ Leilani Farha ដែលបានចេញនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ត្រង់ចំនុចលេខ១ ២ ៦ ៧ ៨ ៩ និង ១០។
- ធានាឱ្យបាននូវការអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីអធិប្បាយរបស់អង្គការសហប្រជាជាតិ ជុំវិញគោលការណ៍ណែនាំ ស្តីអំពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ពិសេសត្រង់ចំនុច III IV V។
- បញ្ឈប់ការបំភិតបំភ័យ ការប្រើហឹង្សា ការគំរាមកំហែងតាមគ្រប់រូបភាព ក្នុងដំណើរនៃការបណ្តេញចេញ និងផ្តល់សិទ្ធិការតវ៉ា តស៊ូមតិដោយសន្តិវិធីដល់ប្រជាពលរដ្ឋ។

## ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាគួរបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធិជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពិនិត្យ និងតាមដានដំណើរការនៃការបណ្តេញចេញនៅកម្ពុជា ដើម្បីលើកស្ទួយ និងការការពារសិទ្ធិទទួលបានលំនៅឋានសមរម្យរបស់ជនទាំងឡាយណាដែលរស់នៅលើទឹកដីកម្ពុជា ព្រមទាំងបន្តផ្តល់ការគាំទ្រដល់ការបំពេញកាតព្វកិច្ចរបស់រដ្ឋាភិបាល ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

# ផ្នែកទី២

# ការបណ្តេញចេញ និងសំណង

## មាតិកា


១.សេចក្តីផ្តើម..........................................................................................២៧

២. វិធីសាស្ត្រស្រាវជ្រាវ ....................................................................................២៨

៣.សហគមន៍ និងសំណងដែលបានផ្តល់..............................................................៣០

៤. ច្បាប់អន្តរជាតិ..........................................................................................៣៣

៥. ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា.....................................................................៣៤

៦.ការវិភាគសំណងដែលផ្តល់ឱ្យសហគមន៍ដែលត្រូវបានបណ្តេញចេញ..............................៣៥

៧. អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា.........................................................៣៨

# ១. សេចក្ដីផ្ដើម



របាយការណ៍ការពិត និងតួលេខនេះ ផ្ដើការពិនិត្យទៅលើសំណងក្នុងការបណ្ដេញចេញដែលផ្ដល់ដល់សហគមន៍ក្រីក្រនៅទីក្រុងភ្នំពេញចាប់ពីឆ្នាំ២០០៦ មក។ ការស្រាវជ្រាវពីមុនៗដែលធ្វើឡើងដោយអង្គការសមាគមធាងត្នោត និងគួរឱ្យកត់សម្គាល់បំផុតក្នុងឆ្នាំ២០២១[១] បានរកឃើញថាជានិច្ចកាល ស្ទើតែគ្មានភាពជាក់លាក់ណាមួយចំពោះរបៀបវារៈនៃការទូទាត់ និងផ្ដល់សំណងសម្រាប់សហគមន៍ក្រីក្រ និងអ្នកដែលត្រូវបានរងការបណ្ដេញចេញផ្សេងទៀតទេ។



ជាក់ស្ដែងនៅពេលមានការផ្ដល់សំណងជាដីជាថ្នូរនឹងការបណ្ដេញចេញ យើងសង្កេតឃើញមានភាពខុសគ្នាយ៉ាងខ្លាំងចំពោះទំហំដីដែលផ្ដល់ជូនជាសំណងនោះ ដោយភាគច្រើនយើងមិនដឹងថា តើការគណនាទំហំដីសំណងក្នុងករណីបណ្ដេញចេញនីមួយៗ ផ្អែកទៅលើមូលដ្ឋានអ្វីខ្លះនោះទេ។ [២]ការណ៍នេះអាចធ្វើឱ្យការរំលោភសិទ្ធិមនុស្សកាន់តែធ្ងន់ធ្ងរ ជាពិសេសសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានលំនៅឋានសមរម្យ និងសំណងគ្រប់គ្រាន់។

[១] អង្គការសមាគមធាងត្នោត, ការបណ្ដេញចេញ និងការផ្លាស់ប្ដូរលំនៅឋាន ឆ្នាំ២០២១, អាចរកបានតាមរយៈ៖ https://media.business-humanrights.org/media/documents/files/documents/STT-Eviction-and-Relocation_ENG_Final.pdf

# ២. វិធីសាស្ត្រស្រាវជ្រាវ





អង្គការសមាគមធាងត្នោត បានពិនិត្យសិក្សាយ៉ាងម៉ត់ចត់ទៅលើច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីឈ្វេងយល់ឱ្យបានច្បាស់ពីដំណើរការនៃការបណ្តេញចេញការតាំងទីលំនៅថ្មី និងសំណង។ យើងក៏បានធ្វើការសិក្សា និងពិនិត្យយ៉ាងហ្មត់ចត់លើឯកសារ និងរបាយការណ៍សារព័ត៌មានផ្សេងៗដែលមានស្រាប់ ដើម្បីធ្វើការវាយតម្លៃទៅលើការអនុវត្តចំពោះការទូទាត់សំណង កន្លងមករបស់អាជ្ញាធរ។

អង្គគការសមាគមធាងត្នោត បានពិនិត្យ និងសិក្សាឡើងវិញលើឯកសារស្រាវជ្រាវផ្ទៃក្នុង និងករណីនៃការបណ្តេញចេញមុនៗរបស់ខ្លួនទាក់ទងនឹងសហគមន៍ដែលប្រឈមមុខនឹងការបណ្តេញចេញ រួមទាំងករណីនៃការបណ្តេញចេញថ្មីៗជាច្រើនទៀត។ ចុងក្រោយ អង្គការសមាគមធាងត្នោតបានវាយតម្លៃករណីដែលជាចំណុចផ្តោតរបស់អង្គការសិទ្ធិមនុស្សផ្សេងទៀត ជាពិសេសលើករណីដែលទាក់ទិននឹងការបណ្តេញចេញ និងសំណង។ វិធីសាស្ត្រទាំងនេះធានាបាននូវការឈ្វេងយល់ច្បាស់លាស់អំពីស្ថានភាពច្បាប់ ប្រវត្តិសាស្ត្រ និងស្ថានភាពបច្ចុប្បន្ននៃការបណ្តេញចេញដោយបង្ខំនៅកម្ពុជា។

បញ្ជាក់៖ ការសិក្សានេះត្រូវបានធ្វើឡើងក្នុងខែឧសភា ដល់ខែកក្កដា ឆ្នាំ 2023 ដែលយើងបានជ្រើសរើសករណីបណ្ដេញចេញ និងការសងសំណងចំនួន ៩ករណី ដែលកើតឡើងចាប់ពីឆ្នាំ២០០៦ មក ដើម្បីយកមកសិក្សាពិនិត្យ ។

# ៣. សហគមន៍ និងសំណងដែលបានផ្តល់

តារាងនេះបង្ហាញពីទិដ្ឋភាពទូទៅនៃសហគមន៍ដែលបានទទួលសំណងសម្រាប់ការបណ្តេញចេញ និងអ្វីដែលមាននៅក្នុងកញ្ចប់សំណងនីមួយៗ។

| ល.រ | សហគមន៍ដែលត្រូវបានបណ្តេញចេញ | ឆ្នាំបណ្តេញចេញ | ទីតាំងលំនៅឋានថ្មី | ចំនួនគ្រួសារ | សំណង | ព័ត៌មានផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | សហគមន៍សម្បុកចាបស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | ២០០៦ | ភូមិអណ្តូងថ្មី សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ (ប្រហែល២០ គីឡូម៉ែត្រពីទីតាំងមុន) | ១៤៦៥ គ្រួសារ (ទិន្នន័យពីសាលារាជធានីភ្នំពេញ) | សាលារាជធានីភ្នំពេញ បានផ្តល់ដីចំនួន ៧៧៧ ឡូតិ៍ ដល់សហគមន៍។ គ្រួសារនីមួយៗទទួលបានដីទំហំ ៤x៦ម៉ែត្រ។ (មិនមានហេដ្ឋារចនាសម្ព័ន្ធនៅកន្លែងតាំងទីលំនៅថ្មីទេនៅពេលនោះ។) | ការបណ្តេញចេញដោយបង្ខំត្រូវបានចាត់ចែង របស់សាលា រាជធានីភ្នំពេញ |
| ២ | សហគមន៍ដីក្រហម ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ប្រជាសហគមន៍នេះបានមកតាំងទីលំនៅដំបូងនៅដីក្រហមក្នុងឆ្នាំ ១៩៨០ | ២០០៩ | ភូមិដំណាក់ត្រយឹងសង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ | ជិត៤០០ គ្រួសារ | អ្នក ដែលត្រូវបានបណ្តេញចេញត្រូវបានផ្តល់ជូនផ្ទះល្វែងថ្មី ឬសំណងហិរញ្ញវត្ថុដោយក្រុមហ៊ុន 7NG ក្នុងតម្លៃប៉ាន់ស្មាន ២៣៤ ដុល្លារក្នុងមួយម៉ែត្រការ៉េ។ | នេះជាការបណ្តេញចេញដោយបង្ខំរៀបចំចាត់ចែងឡើងសាលារាជធានីភ្នំពេញនិង ក្រុមហ៊ុន 7NG ដែលជាក្រុមហ៊ុនឯកជន។ |
| ៣ | សហគមន៍បឹងកក់ ស្ថិតក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | ២០០៨ | គ្រួសារមួយចំនួនបានផ្លាស់ទីលំនៅទៅនៅភូមិដំណាក់ត្រយឹង ចម្ងាយប្រហែល ២៥គីឡូម៉ែត្រពីទីតាំងមុន។ គ្រួសារមួយចំនួនបានទទួលយកសំណងជាសាច់ប្រាក់ ហើយបន្ទាប់មកបានប្តូរទីលំនៅរស់នៅរាយប៉ាយពេញទីក្រុង។ | ៤២៥២ គ្រួសារ[៣] | ប្រជាសហគមន៍ត្រូវបានផ្តល់ជម្រើសដូចខាងក្រោម៖ ត្រូវទទួលយកសំណងប្រមាណ៨.៥០០ ដុល្លាអាមេរិក។ ទទួលយកការអភិវឌ្ឍកែលម្អនៅនឹងកន្លែង ឬផ្លាស់ប្តូរទីលំនៅដោយទទួលយកសំណងជាដី និងលំនៅឋាន (ផ្ទះល្វែង ៤ x ១២ ម៉ែត្រ) នៅទីតាំងលំនៅឋានថ្មីនៅភូមិដំណាក់ត្រយឹងដែលមានចំងាយប្រហែល២៥ គីឡូម៉ែត្រពីកណ្តាលក្រុង។[៤] | បឹងនេះមានផ្ទៃក្រឡាទំហំជាង ១៣៣ ហិកតា។ |

[៣] សេចក្តីថ្លែងការណ៍៖ កិច្ចសន្យាជួលដីបឹងកក់រំលោភច្បាប់កម្ពុជា|កម្ពុជា|លីកាដូ (licadho-cambodia.org)Statement: Boeung Kok

[៤] សេចក្តីថ្លែងការណ៍៖ កិច្ចសន្យាជួលដីបឹងកក់រំលោភច្បាប់កម្ពុជា|កម្ពុជា|លីកាដូ (licadho-cambodia.org)Statement: Boeung Kok

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | បឹងតាមោក សហគមន៍ភូមិកោះរងៀង សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ សហគមន៍បានមកតាំងទីលំនៅចន្លោះពីឆ្នាំ១៩៨៥ ដល់ ១៩៩០។ | ក្នុងខែធ្នូ ឆ្នាំ ២០២១ ប្រជាពលរដ្ឋចំនួន១៣ គ្រួសារ ត្រូវបានបណ្តេញចេញ។<br><br>ក្នុងខែ ឧសភា ឆ្នាំ២០២២ ប្រជាពលរដ្ឋចំនួន១០ គ្រួសារ ត្រូវបានបណ្តេញចេញ។ | ប្រជាពលរដ្ឋចំនួន ១៣ គ្រួសារ ផ្លាស់ទីលំនៅរស់នៅភូមិទួល សង្កាត់ពន្សាំងខណ្ឌព្រែកព្នៅ។<br><br>ប្រជាពលរដ្ឋចំនួន១០ ផ្លាស់ទៅរស់នៅភូមិស្រែដូនតូច។ | ២៣ គ្រួសារ | ប្រជាពលរដ្ឋចំនួន ១៣ គ្រួសារទទួលបានប្រាក់ចំនួន ៥០០ ដុល្លារ និងដីទំហំ៥x១៨ម៉ែដែលមានប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធ ក្រៅផ្លូវការ។<br><br>ប្រជាពលរដ្ឋចំនួន ១០គ្រួសារ ទទួលបានប្រាក់សំណងចំនួន១៣.០០០ ដុល្លារ រួមជាមួយនឹងដីទំហំ៥x២៥ -៥x៣០ ម៉ែត្រ (គ្មានប័ណ្ណកម្មសិទ្ធិផ្លូវការ) និងផ្ទះដែលសាងសង់រួចបាន ៥០% ពីអាជ្ញាធរ។ | មិនមាន |
| ៥ | សហគមន៍ បឹងតាមោក។ ប្រជាពលរដ្ឋមកតាំងទីលំនៅតាំងពីឆ្នាំ១៩៧៩ នៅភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញ។ | ២០២៣ | ទីតាំងលំនៅឋានថ្មីស្ថិតនៅសង្កាត់សំរោងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ប្រហែល២ គីឡូម៉ែត្រពីទីតាំងចាស់។ | ២៦ គ្រួសារ | អ្នកដែលត្រូវបានបណ្តេញចេញទទួលបានប្រាក់ចំនួន ១០.០០០ ដុល្លារ ដើម្បីសាងសង់ផ្ទះថ្មី (៤.២x១៥ ម៉ែត្រ) លើផ្ទៃដីទំហំ (៤.៥ x១៨ ម៉ែត្រ) | មិនមាន |
| ៦ | អាកាសយានដ្ឋានថ្មី៖ ឃុំជើងកែប និងឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ | ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ | ភូមិកំពង់តាឡុង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ | ១០១ គ្រួសារ | អ្នកដែលត្រូវបានបណ្តេញចេញ ត្រូវបានផ្តល់សំណងចំនួន៨ ដុល្លារក្នុងមួយម៉ែត្រការ៉េ។ ពួកគេក៏ត្រូវបានផ្តល់ជូនផ្ទះថ្មី (៥x៨ម៉ែត្រ) នៅលើដីឡូតិ៍ទំហំ (៥x២០ ម៉ែត្រ) ដែលមានប្លង់កម្មសិទ្ធិស្របច្បាប់ ឬប្លង់រឹងផងដែរ។ | មិនមាន |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | អាកាសយានដ្ឋានថ្មី៖ ឃុំបឹងខ្យាង ឃុំអំពៅព្រៃឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងឃុំពុតសស្រុកបាទី ខេត្តតាកែវ | ក្នុងឆ្នាំ២០១៨ សហគមន៍ត្រូវបានទទួលការជូនដំណឹងអំពីការ បណ្តេញចេញជាបន្ទាន់ដើម្បីបើកផ្លូវសម្រាប់ការសាងសង់អាកាសយានដ្ឋានអន្តរជាតិថ្មី។ | មិនដឹង | ៣៣០ គ្រួសារ | អ្នកដែលត្រូវបានបណ្តេញចេញបានទទួលសំណើផ្តល់សំណងចំនួន៨ ដុល្លារក្នុងមួយម៉ែត្រការ៉េ។ ប្រជាពលរដ្ឋត្រូវបង្ខំចិត្តទទួលយកសំណងនោះ ហើយចាកចេញពីព្រោះគ្មានដំណោះស្រាយផ្សេងទៀតត្រូវបានផ្តល់ជូនពួកគេទេ។ | មិនមាន |
| ៨ | ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០២១ | មិនដឹង | ៥៦២៧ គ្រួសារ[៥] | អ្នកដែលត្រូវបានបណ្តេញចេញត្រូវបានផ្តល់សំណងជាសាច់ប្រាក់ចាប់ពី ៣0.000 ដុល្លារដល់ ៤0.000ដុល្លារ។ ទោះជាយ៉ាងណាក៏ដោយ ចំនួននេះស្មើតែពាក់កណ្តាលនៃតម្លៃទ្រព្យសម្បត្តិដែលបាត់បង់ និងបំណុលធនាគាររបស់ពួកគេប៉ុណ្ណោះ។ | មិនមាន |
| ៩ | អគារស (ប៊ូឌិង)ប្រជាពលរដ្ឋបានចាប់ផ្តើមមកតាំងទីលំនៅក្នុងឆ្នាំ ១៩៧៩ និងពេញទសវត្សទី៨០ ។ ស្ថិតនៅភូមិ១ និងភូមិ២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន កណ្ដាលរាជធានីភ្នំពេញ។ | ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧[៦] | មានពាក្យចចាមអារ៉ាមថា ប្រជាបលរដ្ឋទាំងនេះត្រូវបានបណ្តេញចេញឱ្យទៅរស់នៅភូមិរុងរឿង[៧] | លើកដំបូង ៥៣២ គ្រួសារ លើកទី២ ចំនួន៤៩៣ គ្រួសារ[៨] | អ្នកដែលត្រូវបានបណ្តេញចេញទទួលបានសាច់ប្រាក់ចាប់ពី២0.000 ដល់ ៧0.000ដុល្លារ។<br><br>អ្នកដែលត្រូវបានបណ្តេញចេញក៏បានទទួលប្រាក់សំណងចំនួន១៤00 ដុល្លារក្នុងមួយម៉ែត្រការ៉េសម្រាប់ការបាត់បង់ផ្ទះល្វែងរបស់ពួកគេដែរ។[៩] | មិនមាន |

[៥] រដ្ឋាភិបាលការពារការរុះរើផ្ទះសម្រាប់ផ្លូវល្បឿនលឿន, ខេមមូឌៀនេស, ២ វិច្ឆិកា ២០២១, អាចរកបាននៅ៖ https://cambodianess.com/article/government-defends-demolishing-houses-for-expressway
[៦] ការកាន់កាប់អគារពណ៌ស, ភ្នំពេញប៉ុស្តិ៍, ៤ កក្កដា ២០១៧, អាចរកបាននៅ៖ https://www.phnompenhpost.com/national/white-building-holdouts
[៧] អ្នករស់នៅអគារប៊ូឌីងផ្តល់ផ្ទះថ្មីនៅជ្រោយចង្វារ, ភ្នំពេញប៉ុស្តិ៍, ៤ កក្កដា ២០១៧, អាចរកបាននៅ៖ https://www.phnompenhpost.com/national/white-building-residents-offered-new-chroy-changvar-homes
[៨] ដូចខាងលើ លេខ៦
[៩] ការវាយកំទេចរៀបចំអគារស, ភ្នំពេញប៉ុស្តិ៍, ១៣ កក្កដា ២០២៣, អាចរកបាននៅ៖ https://www.phnompenhpost.com/national/demolition-derby-preparing-white-building

# ៤. ច្បាប់អន្តរជាតិ



យោងតាមច្បាប់អន្តរជាតិរដ្ឋត្រូវធានាថា សំណងត្រូវបានធានាសម្រាប់គ្រួសារដែលទទួលរងការបណ្តេញចេញ។[១០] នេះរាប់បញ្ចូលទាំងការផ្តល់ប្រាក់សំណងសម្រាប់ "ទ្រព្យសម្បត្តិទាំងផ្ទាល់ខ្លួន និងជាក់ស្តែង"។[១១]នៅពេលដែលរដ្ឋាភិបាលកម្ពុជាបណ្តេញប្រជាពលរដ្ឋចេញពីសហគមន៍ ពលរដ្ឋត្រូវតែធានាថាទទួលបានសំណង។ រាល់ការបាត់បង់ទ្រព្យសម្បត្តិ ការងារ ដីធ្លី និងទំនិញត្រូវតែមានសំណង។

ករណីមួយចំនួន ការផ្តល់ផ្ទះ គឺជាផ្នែកមួយនៃសំណង។ ការបណ្តេញចេញមិនត្រូវក្លាយជាមូលហេតុធ្វើឱ្យមនុស្សគ្មានផ្ទះសម្បែងឡើយ។[១២]រដ្ឋ ឬអង្គភាពពាក់ព័ន្ធដែលដឹកនាំដំណើរការបណ្តេញចេញ ត្រូវតែផ្តល់លំនៅឋានថ្មីនៅកន្លែងផ្សេងទៀត ដល់ពលរដ្ឋដែលត្រូវរងការបណ្តេញចេញ។ លើសពីនេះ ជាឧទាហរណ៍ ការផ្តល់ដីជាសំណងសម្រាប់កសិករ ក៏អាចត្រូវប្រើប្រាស់ជាមធ្យោបាយរ៉ាប់រងការខាតបង់ ឬទូទាត់សំណងផងដែរ។[១៣]



[១០] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ (CESCR), យោបល់ទូទៅលេខ៧៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា១១.១)៖ ការបណ្តេញចេញដោយបង្ខំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ E/1998/22, កថាខណ្ឌ១៣។
[១១] ដូចខាងលើ
[១២] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ (CESCR), យោបល់ទូទៅលេខ៧៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា១១.១)៖ ការបណ្តេញចេញដោយបង្ខំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ E/1998/22, កថាខណ្ឌ១៦។
[១៣] ដូចខាងលើ

# ៥. ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា



យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣) ពលរដ្ឋគ្រប់រូបមានសិទ្ធិក្នុងការទទួលបានការទទួលស្គាល់ និងគោរពសិទ្ធិមនុស្សរបស់ខ្លួន។[១៤] ចំពោះការបណ្តេញចេញ និងការតាំងទីលំនៅថ្មី មាត្រា៤៤ ចែងថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ។[១៥]

កម្មសិទ្ធិអាចដកហូត ឬរឹបអូសបានដោយរដ្ឋ។ ទោះជាយ៉ាងនេះក្តី ការរឹបអូសនេះអាចធ្វើបាន លុះត្រាតែការរឹបអូសនោះធ្វើឡើង ដើម្បីប្រយោជន៍សាធារណៈ។ លើសពីនេះ សំណងសមស្រប និងយុត្តិធម៌ ត្រូវបានតម្រូវអោយផ្តល់អោយក្នុងករណីការរឹបអូសត្រូវបានធ្វើឡើង។[១៦]

ក្រៅពីរដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល (ឆ្នាំ២០០១) ក៏ផ្តល់ការការពារ និងធានាសំណងពីការរឹបអូសដីធ្លីពីប្រជាពលរដ្ឋដោយរដ្ឋដែរ ដោយថា ការរឹបអូសដីធ្លីអាចធ្វើបាន តែក្នុងករណីសម្រាប់ប្រយោជន៍សាធារណៈ និងតែក្នុងករណីដែលសំណងសមស្រប និងយុត្តិធម៌ត្រូវបានផ្តល់ប៉ុណ្ណោះ។[១៧]

ពុំមានភាពច្បាស់លាស់ទេថា តើសំណងសមស្របត្រូវសម្រេចដោយរបៀបណាទេ ប៉ុន្តែច្បាប់ស្តីពីអស្សាមិករណ៍ចែងថា សំណងសមស្របត្រូវផ្អែកលើតម្លៃទីផ្សារ ឬចំណាយជំនួសដែលកំណត់ដោយគណៈកម្មាធិការ ឬភ្នាក់ងារឯករាជ្យណាមួយ។[១៨]

---

[១៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៣១។

[១៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៤៤។

[១៦] ដូចខាងលើ។

[១៧] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា៥។

[១៨] ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ មាត្រា២២។

ទោះបីជាច្បាប់អន្តរជាតិតម្រូវឱ្យកម្ពុជាដាក់បញ្ចូលការការពារបញ្ចៀសការបណ្តេញចេញដោយ[១៩]បង្ខំ ទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនក៏ដោយ ក៏មានច្បាប់កម្ពុជាតិចតួចណាស់ ដែលផ្តល់ការការពារសហគមន៍ក្រីក្រ ឬប្រជាជនពីការបណ្តេញចេញដោយបង្ខំ។ ច្បាប់កម្ពុជាមិនមានបញ្ញត្តិគ្រប់គ្រាន់ ដើម្បីជួយសហគមន៍ក្រីក្រឱ្យទទួលបានលំនៅឋាន ឬទទួលបានសំណងសមរម្យ នៅពេលពួកគេប្រឈមនឹងការបណ្តេញចេញទេ។ ជាលទ្ធផល អ្វីដែលយើងព្យាយាមគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះនោះគឺ គ្មានទំរង់ជាក់លាក់ណាមួយត្រូវបានប្រើប្រាស់ដោយអាជ្ញាធរ ឬរដ្ឋាភិបាលក្នុងការទូទាត់សំណងជូនប្រជាពលរដ្ឋ នៅពេលមានការបណ្តេញចេញទេ។ ដូច្នេះហើយ ការផ្តល់សំណងគ្រប់គ្រាន់ និងសមស្រប និងសិទ្ធិមានលំនៅឋានគ្រប់គ្រាន់ ចាំបាច់ត្រូវលើកកម្ពស់ក្នុងច្បាប់កម្ពុជា។

# ៦. ការវិភាគសំណងដែលផ្តល់ឱ្យសហគមន៍ដែលត្រូវបានបណ្តេញចេញ



## ការទទួលបានព័ត៌មានអំពីការគណនាសំណង

សហគមន៍ដែលអង្គការសមាគមជាងត្នោតបានជួបពិភាក្សា បានពិពណ៌នាយ៉ាងស៊ីសង្វាក់គ្នាថា ពួកគេមិនទទួលបាន ឬខ្វះព័ត៌មានគ្រប់គ្រាន់ ពីដំណើរការនៃការទូទាត់សំណងនៅពេលមានការបណ្តេញចេញ។ ទោះបីជាច្បាប់ស្តីពីអស្សាមិករណ៍សង្កត់ធ្ងន់លើការបង្កើតគណៈកម្មាធិការឯករាជ្យ ដើម្បីធ្វើការវាយតម្លៃទៅតាមតម្លៃទីផ្សារក៏ដោយ ក៏សហគមន៍ដែលរងការបណ្តេញចេញទទួលបានព័ត៌មានតិចតួចបំផុតទាក់ទងនិងវង្វាយតម្លៃនោះ ដែលធ្វើឱ្យពួកគេមិនអាចពន្យល់អង្គការសមាគមជាងត្នោតអំពីរបៀបដែលរដ្ឋាភិបាល ឬក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការបណ្តេញចេញ សម្រេចលើតួលេខនៃថ្លៃសំណងដែលបានស្នើឡើងបាន។ ការទទួលបានព័ត៌មានទាក់ទិននឹងការបណ្តេញចេញ មានសារៈសំខាន់ណាស់សម្រាប់ការទប់ស្កាត់ការបណ្តេញបខណ្ឌអន្តរជាតិ។[20] ទោះបីជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះគូសបញ្ជាក់ថា នៅកម្ពុជា វាជារឿងសាមញ្ញទៅហើយ ដែលសហគមន៍ទទួលបានព័ត៌មានតិចតួច ឬមិនទទួលបានព័ត៌មានទាក់ទងនឹងរបៀបនៃការគណនាសំណង។

## ការខ្វះខាតភាពច្បាស់លាស់ដែលនាំឱ្យមានភាពមិនជាក់លាក់

ដំណើរការនៃការទូទាត់សំណងខ្វះភាពជាក់លាក់ដែលងាយនាំឱ្យមានភាពលម្អៀង ការកេងប្រវ័ញ្ច និងអយុត្តិធម៌។ ឧទាហរណ៍៖ នៅពេលដែលប្រជាពលរដ្ឋនៅអគារប៊ូឌីងត្រូវបានបណ្តេញចេញ ពួកគេបានទទួលប្រាក់សំណងច្រើនក្រាស់ក្រែល បើប្រៀបធៀបនឹងសហគមន៍ផ្សេងទៀតដែលមានស្ថានភាពស្រដៀងគ្នា នៅទូទាំងរាជធានីភ្នំពេញ។ ដូច្នេះ សហគមន៍ដែលទទួលបានសំណងតិចជាង ជាញឹកញាប់មានអារម្មណ៍ថា មានការរើសអើង

[20] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ (CESCR), យោបល់ទូទៅលេខ៧៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា១១.១)៖ ការបណ្តេញចេញដោយបង្ខំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ E/1998/22, កថាខណ្ឌ១៥។



លើពួកគេ។ ការគ្មានគោលនយោបាយស្តីពីសំណងច្បាស់លាស់របស់រដ្ឋាភិបាលកម្ពុជា បាននាំឱ្យមានបញ្ហាការរើសអើងនេះកើតឡើង។ បើគ្មានការកែប្រែច្បាប់ ឬគ្មាគោលនយោបាយច្បាស់លាស់នោះទេ នោះការបណ្តេញចេញនាពេលអនាគតប្រាកដជានឹងបំពានច្បាប់អន្តរជាតិ និងបង្កឱ្យមានការរើសអើងជាបន្តទៀត។

## សំណងក្នុងទម្រង់ជាដីធ្លី ឬថវិកា

សហគមន៍មួយចំនួន បានទទួលសំណងទាំងជាដី និងប្រាក់ ចំណែកសហគមន៍មួយចំនួនទៀតទទួលបានតែដី ឬប្រាក់ប៉ុណ្ណោះ។ មិនមានមូលហេតុច្បាស់លាស់ បញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នា ឬភាពមិនជាក់លាក់នៃប្រភេទសំណងដែលផ្តល់ដល់សហគមន៍ទេ ពីព្រោះកន្លងមកមិនមានការពន្យល់ពីការទូទាត់សំណងជាលាយលក្ខណ៍អក្សរ។ គួរកត់សម្គាល់ថា ការទទួលបានសំណងក្នុងទម្រង់ជាដីធ្លី អាចមានអំណោយផលច្រើនសម្រាប់សហគមន៍មួយចំនួន។ ឧទាហរណ៍៖ សហគមន៍កសិកម្មអាចចង់បានដីស្រែចំការច្រើនជាង ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ ចំណែកសហគមន៍ដទៃទៀតអាចមានតម្រូវការផ្សេងពីនេះ។ ទោះបីជាយ៉ាងនេះក្តី គ្មានភស្តុតាងណាមួយបង្ហាញថា អាជ្ញាធរកម្ពុជាបានយកកត្តាទាំងនេះទៅពិចារណាឡើយ។

## គ្មានការផ្តល់លំនៅឋានសម្រាប់ជនដែលប្រឈមនឹងស្ថានភាពគ្មានទីជម្រក

ជាចុងក្រោយ មានតែសហគមន៍មួយប៉ុណ្ណោះដែលត្រូវបានផ្តល់លំនៅឋាននៅទីតាំងលំនៅឋានថ្មី បើទោះបីជាវាជាការតម្រូវ សម្រាប់ជនដែលប្រឈមនឹងអនាថភាពក្រោមច្បាប់អន្តរជាតិក៏ដោយ។ ការណ៍នេះមិនត្រឹមតែរំលោភសិទ្ធិទទួលបានលំនៅឋានសមរម្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យសមាជិកសហគមន៍ជាច្រើនប្រឈមនឹងអនាថភាពគ្មានផ្ទះសំបែង ឬជំពាក់បំណុលទៀតផង ដោយសារ

ពួកគេត្រូវខ្ចីប្រាក់ ដើម្បីសាងសង់ផ្ទះ។ ការផ្តល់លំនៅឋាន គឺជាការតម្រូវអប្បបរមា និងមិនអាចបដិសេធបានទេ នៅពេលដែលបុគ្គលម្នាក់ៗពុំមានលទ្ធភាពផ្គត់ផ្គង់លំនៅឋានដោយខ្លួនឯង។ គេមិនគួរចាត់ទុកវាជាសំណងទេ ប៉ុន្តែគួរចាត់ទុកវាជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សដែលត្រូវតែគោរពក្នុងអំឡុងដំណើរការតាំងលំនៅឋានថ្មី។

# ៧. អនុសាសន៍ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

- បង្កើតគោលនយោបាយច្បាស់លាស់ស្តីពីសំណង់សម្រាប់ការបណ្តេញចេញ ដែលគិតគូរពីកម្មសិទ្ធិដីធ្លី ការយល់ដឹងផ្នែកវប្បធម៌ និងសំណងជារូបិយវត្ថុ ដូចបានកំណត់ដោយច្បាប់អន្តរជាតិ។
- ធានាថាគ្មានជនណាម្នាក់ក្លាយជាជនអនាថា ឬប្រឈមគ្រោះថ្នាក់នៃអនាថភាព ដោយសារការបណ្តេញចេញ។ ការណ៍នេះអាចសម្រេចបាន ដោយការអនុវត្តច្បាប់ដែលការពារប្រជាពលរដ្ឋពីការបណ្តេញចេញដោយបង្ខំ និងធានាជំនួយលំនៅឋានសម្រាប់អ្នកដែលមិនមានលទ្ធភាពធ្វើលំនៅឋានដោយខ្លួនឯង ស្របតាមស្តង់ដារអន្តរជាតិ។
- លើកកម្ពស់តម្លាភាព សង្គតិភាព និងគណនេយ្យភាពក្នុងដំណើរការធ្វើសេចក្តីសម្រេចទាក់ទងនឹងសំណង ដោយផ្សព្វផ្សាយជាសាធារណៈ រាល់ព័ត៌មាន និងសេចក្តីសម្រេចពាក់ព័ន្ធ ដែលបានធ្វើឡើងកន្លងមក។
- អនុសាសន៍ខាងលើនេះ ត្រូវបានធ្វើឡើងសម្រាប់រាជរដ្ឋាភិបាល និងគួរត្រូវបានទទួលស្គាល់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងសាលារាជធានីភ្នំពេញផង។



# ផ្នែកទី៣

# ការផ្លាស់ប្តូរលំនៅឋាន និងបំណុល

## មាតិកា


១. សេចក្តីផ្តើម ....................................................................................................៤២

២. វិធីសាស្ត្រស្រាវជ្រាវ................................................................................................៤៣

៣. លទ្ធផលរកឃើញសំខាន់ៗ.......................................................................................៤៤

៤. ការសន្និដ្ឋាន.........................................................................................................៤៨

៥. អនុសាសន៍...........................................................................................................៥០

# ១. សេចក្តីផ្តើម



អនុលោមតាមច្បាប់អន្តរជាតិ កម្ពុជាមានកាតព្វកិច្ចធានាសិទ្ធិទទួលបានលំនៅឋានសមរម្យ។ នេះមានន័យថា ការបណ្តេញចេញដោយបង្ខំត្រូវហាមឃាត់ជាសាកល ហើយ ក្នុងចំណោមកាតព្វកិច្ចផ្សេងទៀត រដ្ឋាភិបាលត្រូវកំណត់ឱ្យមានការបង្កើតទីតាំងលំនៅឋានថ្មីដែលធានាបាននូវសិទ្ធិទទួលបានលំនៅឋានសមរម្យ។

លំនៅឋានមិនមែនគ្រាន់តែជាតម្រូវការជាមូលដ្ឋានប៉ុណ្ណោះទេ វាមានសារសំខាន់ណាស់សម្រាប់ការការពារ និងលើកកម្ពស់សិទ្ធិផ្សេងទៀត។ អវត្តមានសិទ្ធិទទួលបានលំនៅឋានសមរម្យអាចនាំឱ្យមានការរំលោភសិទ្ធិផ្សេងទៀត។ ការស្រាវជ្រាវនេះលាតត្រដាងឱ្យឃើញថា បុគ្គលដែលត្រូវបានបណ្តេញចេញដោយបង្ខំ និងមិនត្រូវបានផ្តល់លំនៅឋាននៅទីតាំងលំនៅឋានថ្មី បានធ្លាក់ខ្លួនជំពាក់បំណុលគេយ៉ាងធ្ងន់ធ្ងរ។ បំណុលទាំងនេះបណ្តាលឱ្យពួកគេខ្វះខាតស្បៀងអាហារ បង្កឱ្យមានពលកម្មកុមារដោយបង្ខំ និងបណ្តាលឱ្យកុមារបោះបង់ការសិក្សា ជាដើម។

ការស្រាវជ្រាវនេះក៏បានគូសបញ្ជាក់ដែរថា ប្រជាពលរដ្ឋខ្មែរដែលជាជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំនៅតែជួបប្រទះការលំបាកជាបន្តនៅទីតាំងលំនៅឋានថ្មី ដោយសារការខ្វះខាតលំនៅឋានរស់នៅ ឬមូលដ្ឋានអនាម័យ ដែលជម្រុញឱ្យពួកគេធ្លាក់ចូលក្នុងវដ្តបំណុលគួរឱ្យព្រួយបារម្ភ។ ដូច្នេះ អាជ្ញាធរកម្ពុជាចាំបាច់ត្រូវចាត់វិធានការឱ្យបានហ្មត់ចត់ថែមទៀត ដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិទទួលបានលំនៅឋានសមរម្យ។



# ២. វិធីសាស្ត្រស្រាវជ្រាវ



នៅខែមិថុនា ឆ្នាំ២០២៣ អង្គការសមាគមធាងត្នោត (STT) បានចុះពិនិត្យដល់ទីតាំងលំនៅឋានថ្មីចំនួនប្រាំមួយ ដើម្បីសម្ភាសប្រជាពលរដ្ឋចំនួន ៣២ នាក់ដែលត្រូវបានបណ្តេញចេញពីលំនៅឋានក្នុងរាជធានីភ្នំពេញ។ ទីតាំងទាំងនេះ ត្រូវបានជ្រើសរើសជាពិសេស ដើម្បីធ្វើការវាយតម្លៃបច្ចុប្បន្នភាព លើគោលនយោបាយទីតាំងលំនៅឋានថ្មីរបស់កម្ពុជា ដោយសារទីតាំងនេះត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាចន្លោះពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញ។

មុនពេលសម្ភាស សមាគមធាងត្នោតបាន បញ្ជាក់ពីគោលបំណងនៃការស្រាវជ្រាវ ពន្យល់ពីតួនាទីរបស់ពួកគេ និងធានាថា អ្នកឆ្លើយសំណួរយល់ពីរបៀបប្រើប្រាស់លទ្ធផលរកឃើញ ដើម្បីតស៊ូមតិជាមួយរដ្ឋាភិបាលកម្ពុជាសម្រាប់ការផ្លាស់ប្តូរគោលនយោបាយ។ អ្នកឆ្លើយសំណួរគ្រប់រូបបានផ្តល់ការព្រមព្រៀងមុនពេលចូលរួម។ បញ្ជីសំណួរស្រាវជ្រាវផ្តោតលើការផ្តល់លំនៅឋានសមរម្យ ដែលកំណត់និយមន័យដោយគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ ស្របតាមច្បាប់អន្តរជាតិ។[២១] ផ្នែកជាបន្តបន្ទាប់នៃបញ្ជីសំណួរពិនិត្យលម្អិតលើបញ្ហាបំណុល និងការរំលោភសិទ្ធិមនុស្សដែលជាផលវិបាករបស់វា។ បញ្ជីសំណួរ រួមជាមួយរូបថតដែលបង្ហាញពីផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់នៅទីតាំងលំនៅឋានថ្មី ត្រូវបានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍នេះ។

ឯកសារនេះមានគោលបំណងចម្បងពិនិត្យលើអយុត្តិធម៌សង្គមដែលកើតចេញពីការបណ្តេញចេញដោយបង្ខំ និងបំណុលនៅក្នុងបរិការណ៍ដែលរដ្ឋាភិបាលមិនបានប្រឹងប្រែងគ្រប់គ្រាន់ ក្នុងការផ្តល់ដំណោះស្រាយ និងសំណងសម្រាប់ឱ្យពលរដ្ឋទទួលបានលំនៅឋានសមរម្យ។

បញ្ជាក់៖ ការសិក្សានេះធ្វើឡើងក្នុងខែកក្កដា ដល់ខែកញ្ញា ឆ្នាំ 2023។

[២១] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ (CESCR), យោបល់ទូទៅលេខ៤៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា១១.១ នៃកតិកាសញ្ញា) ដែលបានអនុម័តនៅក្នុងសម័យប្រជុំលើកទី៦របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១ (មាននៅក្នុងឯកសារ E/1992/23), កថាខណ្ឌ០៨, (a)(b)(c)(d)(e)(f)(g)។

# ៣. លទ្ធផលស្រាវជ្រាវសំខាន់ៗ



## បរាជ័យក្នុងការផ្ដល់ដំណោះស្រាយក្នុងទម្រង់ជាលំនៅឋានសមរម្យ

ការផ្ដល់សំណងក្នុងទម្រង់ជាលំនៅឋានសមរម្យនៅទីតាំងលំនៅឋានថ្មី គឺជាការតម្រូវនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[២២] បើទោះជាយ៉ាងនេះក្ដី ក្នុងចំណោមទីតាំងទាំងប្រាំមួយ មានតែទីតាំងមួយប៉ុណ្ណោះដែលបានបញ្ចូលការផ្ដល់លំនៅឋានមួយផ្នែក ដល់ជនដែលត្រូវបានបណ្ដេញចេញ។[២៣] អ្នកតបសម្ភាសន៍ពីទីតាំងពិសេសនេះបានពណ៌នាអំពីលំនៅឋានដែលគេផ្ដល់ឱ្យថា ជាផ្ទះ "ដែលសាងសង់បានពាក់កណ្ដាល"។

លំនៅឋាននេះរួមមានជញ្ជាំង និងដំបូល ប៉ុន្តែមិនមានទ្វារ បង្អួច ឬកម្រាលឥដ្ឋទេ។ នេះមានន័យថា អ្នករស់នៅត្រូវប្រឈមគ្រោះថ្នាក់ផ្សេងៗ និងកង្វះសុវត្ថិភាព ដោយសារផ្ទះគ្មានមិនមានទ្វារ ឬបង្អួច។ នៅគ្រប់កន្លែងផ្សេងទៀតដែលសមាគមធាងត្នោតបានចុះទៅដល់ អ្នកដែលត្រូវបានបណ្ដេញចេញ មិនត្រូវបានផ្ដល់លំនៅឋានទេ ពោលគឺមានតែដីឡូតិ៍ទទេប៉ុណ្ណោះ។

យោងតាមគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ លំនៅឋានសមរម្យតម្រូវឱ្យមាន៖

១).សន្តិសុខនៃការកាន់កាប់ស្របច្បាប់
២). តម្លៃសមរម្យ
៣). អាចរស់នៅបាន
៤). ងាយស្រួលប្រើប្រាស់
5). នៅជិតសេវានានា និង
៦). ភាពគ្រប់គ្រាន់នៃវប្បធម៌ ។[២៤]

ទោះជាយ៉ាងនេះក្ដី មានតែទីតាំងលំនៅឋានថ្មីចំនួនពីរប៉ុណ្ណោះ ដែលមានទឹក អគ្គិសនី ផ្លូវ សេវាប្រមូលសំរាម និងប្រព័ន្ធលូបង្ហូរទឹកស្អុយ នៅពេលដែលជនដែលត្រូវបានបណ្ដេញចេញ ទៅដល់កន្លែងនោះលើកដំបូង។

ទីតាំងលំនៅឋានថ្មីមានភាពខុសគ្នាចំពោះចម្ងាយទៅកាន់សាលារៀន ដោយទីតាំងមួយ

[២២] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ (CESCR), យោបល់ទូទៅលេខ៧៖ សិទ្ធិមានលំនៅឋានសមរម្យ (មាត្រា១១.១)៖ ការបណ្ដេញចេញដោយបង្ខំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ E/1998/22, កថាខណ្ឌ១៦។
[២៣] សហគមន៍សំពោងកណ្ដាល
[២៤] ឯកសារពិតលេខ ២១ សិទ្ធិរបស់មនុស្សក្នុងការមានលំនៅឋានគ្រប់គ្រាន់, ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, ខែវិច្ឆិកា ២០០៩ , available at: https://www.refworld.org/docid/479477400.html [accessed 3 May 2023]

ចំនួនស្ថិតនៅចម្ងាយរហូតដល់ប្រាំគីឡូម៉ែត្រពីសាលារដ្ឋ។ អ្នកតបសម្ភាសម្នាក់បានប្រាប់សមាគមធាងត្នោតថា កូនរបស់គាត់មិនអាចចូលសិក្សានៅសាលារៀនបានទេ ដោយសារគាត់មិនអាចដើរបានឆ្ងាយ ហើយគ្រួសារក៏មិនមានជម្រើសមធ្យោបាយធ្វើដំណើរសម្រាប់ពួកគេដែរ។ ទីតាំងលំនៅឋានថ្មីទាំងអស់ មិនស្ថិតនៅជិតសួនសាធារណៈ ឬកន្លែងកម្សាន្តទេ។

ទាក់ទងនឹងសន្តិសុខនៃការកាន់កាប់ដីធ្លី ប្រជាពលរដ្ឋទាំងអស់ដែលត្រូវបានសម្ភាសដោយសមាគមធាងត្នោត បានរាយការណ៍ថា ពួកគេមានបង្កាន់ដៃដីធ្លីសម្រាប់ទីតាំងលំនៅឋានថ្មី (ប្លង់ទន់) ប៉ុន្តែពុំមាននរណាម្នាក់មានប្លង់រឹងឡើយ។

## បំណុលដែលបណ្តាលមកពីការមិនផ្តល់ដំណោះស្រាយសមរម្យ

ការខកខានក្នុងការផ្តល់លំនៅឋានសមរម្យដល់អ្នកដែលត្រូវបានបណ្តេញចេញ នាំឱ្យមានបំណុលកើនឡើងគួរឱ្យព្រួយបារម្ភ ក្នុងចំណោមបុគ្គលទាំងនោះ ដោយសារពួកគេខ្វះខាតថវិកាក្នុងការសាងសង់ផ្ទះ និងហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់។ អ្នកដែលត្រូវបានបណ្តេញចេញចំនួន ៩០% បានធ្លាក់ខ្លួនជំពាក់បំណុលគេ។ ការស្រាវជ្រាវនេះបានរកឃើញថា អ្នកចូលរួមចំនួនប្រាំមួយនាក់បានងាកទៅខ្ចីប្រាក់ពីអ្នកឱ្យខ្ចីប្រាក់ឯកជន(អ្នកចងការប្រាក់)[២៥] ប្រាំបីនាក់ងាកទៅខ្ចីប្រាក់ពីធនាគារ ចំណែកអ្នកចូលរួមចំនួន១១នាក់ពឹងពាក់លើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs)។ អ្នកឆ្លើយសំណួរពីរនាក់ត្រូវខ្ចីប្រាក់ពីធនាគារផងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផង ឬពីអ្នកចងការប្រាក់និងពីធនាគារក្នុងពេលដំណាលគ្នា។ អ្នកចូលរួមចំនួនប្រាំនាក់ទៀតក៏បានធ្លាក់ខ្លួនជំពាក់បំណុលតាមរយៈមធ្យោបាយផ្សេងទៀត។ វាជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថា សមាគមធាងត្នោត រួមជាមួយអង្គការសិទ្ធិមនុស្ស និងអ្នកសិក្សាស្រាវជ្រាវដទៃទៀត បានចងក្រងឯកសារអំពីការកេងប្រវ័ញ្ចនៃឧស្សាហកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលបន្ថែមការលំបាកមួយកម្រិតទៀតសម្រាប់អ្នកជំពាក់បំណុលគេទាំងនេះ។

អ្នកឆ្លើយសំណួរបានលើកឡើងថា មូលហេតុចម្បងដែលនាំឱ្យមានបំណុល គឺតម្រូវការសាងសង់ផ្ទះ តភ្ជាប់បណ្តាញទឹក និងអគ្គិសនី និងបង់ថ្លៃសាលាឯកជន។ នេះបង្ហាញថា ការខកខានរបស់រដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់លំនៅឋានសមរម្យដែលគួររួមបញ្ចូលទាំងសេវាជាមូលដ្ឋាន ដូចជាអនាម័យ ទឹក និងអគ្គិសនីផង បានរួមចំណែកដោយផ្ទាល់ ធ្វើឱ្យបុគ្គលទាំងនេះធ្លាក់ខ្លួនជំពាក់បំណុលគេ។ ក្នុងចំណោមអ្នកខ្ចីប្រាក់គេ អ្នកឆ្លើយសំណួរចំនួន២៨ នាក់បានប្រើប្រាស់បង្កាន់ដៃដីរបស់ពួកគេជាទ្រព្យបញ្ចាំ ប្រាប់ព័ត៌មានអំពី។ អ្នកចូលរួមចំនួនបួននាក់ទៀតមិនបានផ្តល់ការឆ្លើយតបទេ។ ដូច្នេះ ប្រសិនបើបុគ្គលទាំងនេះមិនអាចសងប្រាក់កម្ចីរបស់ខ្លួនបានទេ ពួកគេអាចប្រឈមនឹងសម្ពាធឱ្យលក់ផ្ទះ ដើម្បីដោះស្រាយបំណុលដែលជារួមនាំដល់សេណារីយ៉ូនៃការបណ្តេញចេញមួយទៀត។

បន្ទុកនៃការសងបំណុលបង្កើនកម្រិតនៃភាពក្រីក្រដែលអ្នកឆ្លើយសំណួរមួយចំនួនកំពុងជួបប្រទះ និងនាំឱ្យមានការរំលោភសិទ្ធិមនុស្សជាបន្ថែមទៀត។ យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ទីតាំងលំនៅឋានថ្មីមិនគួររួមចំណែក ឬធ្វើឱ្យប្រជាពលរដ្ឋប្រឈមនឹងការរំលោភសិទ្ធិមនុស្សបន្ថែមឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះបានរកឃើញថា បំណុលដែលកើតឡើងដោយសារការខកខានរបស់រដ្ឋាភិបាលក្នុងការផ្តល់លំនៅឋានសមរម្យនាំឱ្យមានការរំលោភសិទ្ធិទាំងនេះ។

[២៥] មាននិយមន័យថា អ្នកឱ្យខ្ចីប្រាក់ឯកជន មិនបានចុះបញ្ជីត្រឹមត្រូវ។

ចំណាយ និងបំណុល។ ការនេះមិនត្រឹមតែធ្វើឱ្យមានការរំលោភសិទ្ធិកុមារប៉ុណ្ណោះទេ ថែមទាំងបង្កើតឱ្យមានពលកម្មកុមារទៀតផង។



បន្ទុកបំណុលក៏មានន័យថា គ្រួសារជាច្រើនត្រូវចំណាយត្បិតត្បៀតជាងមុន។ ប្រជាពលរដ្ឋចំនួន២៧ គ្រួសារបានរាយការណ៍ថា ពួកគេមិនអាចចំណាយច្រើនលើម្ហូបអាហារ ដូចមុនទេ។

៩០% នៃអ្នកខ្ចីប្រាក់ ជាចំនួនដ៏គួរឱ្យកត់សម្គាល់ បានរាយការណ៍ថា អត្រាការប្រាក់ប្រចាំឆ្នាំលើប្រាក់កម្ចីរបស់ពួកគេ មានចាប់ពី១.១% ដល់ ១.៧%។

ក្នុងចំណោមអ្នកឆ្លើយសំណួរទាំង២១ នាក់ អ្នកឆ្លើយសំណួរចំនួន៧ នាក់បានរាយការណ៍ថា ពួកគេត្រូវឱ្យកូនឈប់រៀន ដោយសារការបណ្តេញចេញដោយបង្ខំ និងការតាំងលំនៅឋានថ្មីជាបន្តបន្ទាប់។ ក្នុងចំណោមអ្នកឆ្លើយសំណួរទាំង៧នាក់នេះ អ្នកឆ្លើយសំណួរម្នាក់បានឱ្យកូនឈប់រៀនដោយសារថ្លៃចំណាយ ចំណែកអ្នកឆ្លើយសំណួរប្រាំមួយនាក់ទៀតបានឱ្យកូនឈប់រៀន ដោយសារពួកគេត្រូវការកូនជួយធ្វើការ ដើម្បីគ្រប់គ្រង



## ស្ថានភាពលំបាកនៃស្ត្រីក្រីក្រ៖ ករណីសិក្សារបស់ណារី និងគ្រួសាររបស់នាង

ណារី ជាស្ត្រីម្នាក់រស់នៅសហគមន៍ក្រីក្រ បានផ្លាស់ចេញពីលំនៅឋាននៅក្នុងតំបន់អភិវឌ្ឍន៍បឹងតាមោក (ភូមិសំរោងកណ្តាល) ផ្លាស់មករស់នៅក្នុងភូមិមួយ នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ នាងរស់នៅជាមួយកូនស្រីពីរនាក់ ម្នាក់មានអាយុ១២ ឆ្នាំ ម្នាក់ទៀតអាយុ១៤ ឆ្នាំ។ ចាប់តាំងពីបានតាំងលំនៅឋានថ្មី គ្រួសាររបស់ ណារី ជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃ ដោយសារចំណាយកើនឡើង និងចំណូលធ្លាក់ចុះ។ នាងបានប្រាប់ថា៖

> បន្ទាប់ពីខ្ញុំផ្លាស់មករស់នៅទីនេះ ខ្ញុំត្រូវចំណាយលុយទិញរបស់របរគ្រប់យ៉ាង សូម្បីតែលុយដឹកឈើពីផ្ទះចាស់ទៅកន្លែងថ្មី។

នៅពេលមកដល់ទីតាំងថ្មីភ្លាម ពួកគេពុំមានលទ្ធភាពសាងសង់ផ្ទះទេ ដោយបង្ខំឱ្យណារីខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុក្នុងមូលដ្ឋានមួយ។ ណារី ធ្វើការនៅរោងចក្រ ហើយប្តីរបស់នាងធ្លាប់ជាអ្នកនេសាទនៅបឹងតាមោក។ ក៏ប៉ុន្តែដោយសារចម្ងាយឆ្ងាយពីផ្ទះថ្មីទៅបឹងតាមោក គាត់ត្រូវឈប់នេសាទត្រី។ ដូច្នេះ ប្រាក់ចំណូលរបស់ ណារី តែម្នាក់ឯង ពីការងាររោងចក្រ មិនគ្រប់គ្រាន់សម្រាប់ការចំណាយ លើការរស់នៅប្រចាំថ្ងៃ និងការសងប្រាក់កម្ចី។

> នៅពេលដែលខ្ញុំមិនអាចរកប្រាក់សងធនាគារបាន ខ្ញុំគ្មានជម្រើសអ្វីក្រៅពីខ្ចីប្រាក់បន្ថែមទេ ជួនកាលខ្ចីពីអ្នកចងការប្រាក់ឯកជន។

ដើម្បីទប់ទល់នឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុនេះ គ្រួសាររបស់នាងត្រូវកាត់បន្ថយការចំណាយលើអាហារប្រចាំថ្ងៃហើយម្តងម្កាលខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ដើម្បីសងការប្រាក់កម្ចី។

ណារី បានពន្យល់ថាដោយមើលឃើញការលំបាករបស់ម្តាយ កូនស្រីទាំងពីរនាក់របស់ណារី ដែលរៀនថ្នាក់ទី៦ និងទី៨ បានសម្រេចចិត្តឈប់រៀន ដើម្បីសម្រាលបន្ទុកហិរញ្ញវត្ថុលើគ្រួសារ។ សព្វថ្ងៃ ពួកគេធ្វើការងារកសិកម្ម។ កូនស្រីម្នាក់បានប្រាប់ណារីថា៖ "ម៉ែ! បើម៉ែពិបាក កូនឈប់រៀន ហើយរកការងារធ្វើ"។

ណារីមានការសោកស្តាយយ៉ាងខ្លាំងចំពោះកូនស្រីរបស់គាត់ ដែលជាសិស្សពូកែ ប៉ុន្តែត្រូវបោះបង់ការសិក្សាទៅរកការងារធ្វើ ដោយសារបញ្ហាបំណុលរបស់ឪពុកម្តាយ។ នាងបានពោលពាក្យតម្អូញថា៖ "ខ្ញុំសោកស្តាយណាស់ ពួកគេជាសិស្សពូកែ ប៉ុន្តែខ្ញុំគ្មានលុយទេឱ្យគេរៀន"។



# ៤. ការសន្និដ្ឋាន



គោលនយោបាយស្តីពីផ្លាស់ប្តូរលំនៅឋានបច្ចុប្បន្នរបស់រដ្ឋាភិបាលកម្ពុជា មានលក្ខណៈផ្ទុយស្រឡះពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរពសិទ្ធិមនុស្សក្នុងការមានលំនៅឋានសមរម្យ។ ការស្រាវជ្រាវនេះបង្ហាញថា ទីតាំងលំនៅឋានថ្មីដែលបង្កើតឡើងសម្រាប់សហគមន៍ដែលត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះមិនគោរពតាមស្តង់ដារអន្តរជាតិយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់។ ស្តង់ដារទាំងនេះ តម្រូវឲ្យផ្តល់លំនៅឋានសមរម្យនៅទីតាំងលំនៅឋានថ្មីជាចាំបាច់។

ជាលទ្ធផលនៃការបរាជ័យនេះ អ្នកដែលត្រូវបានបណ្តេញចេញ បានធ្លាក់ខ្លួនជំពាក់បំណុលគេ ជាបន្ទុកមួយដែលមនុស្សជាច្រើនភ័យខ្លាចក្រែងពួកគេមិនអាចទ្រាំទ្របាន។ វិបត្តិបំណុលនេះកំពុងបង្ខំកុមារឱ្យបោះបង់ការសិក្សា។ បំណុលទាំងនេះមិនត្រឹមតែធ្វើឱ្យបញ្ហាសិទ្ធិមនុស្សកាន់តែអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាលទ្ធផលផ្ទាល់នៃការបណ្តេញចេញដោយបង្ខំ និងការខកខានមិនផ្តល់លំនៅឋានសមរម្យដែរ។

ជារួម រដ្ឋាភិបាលកម្ពុជាកំពុងបង្ខំប្រជាពលរដ្ឋរបស់ខ្លួនឱ្យទទួលបន្ទុកផ្ទាល់ខ្លួនលើការទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។







# ៥. អនុសាសន៍



- បង្កើតច្បាប់ដែលហាមឃាត់ការបណ្តេញចេញដោយបង្ខំ និងដែលចែងយ៉ាងច្បាស់អំពីការទទួលខុសត្រូវរបស់រដ្ឋ នៅពេលអនុវត្តការបណ្តេញចេញ រួមទាំងការផ្តល់ទីតាំងលំនៅឋានថ្មីដែលមិននាំឱ្យមានការរំលោភសិទ្ធិមនុស្សជាបន្ថែមទៀត។ ច្បាប់នេះគួរតែពន្យល់លម្អិត ត្រួតពិនិត្យដំណើរការនៃការបណ្តេញចេញ និងគួរតាក់តែងឡើង ដោយមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្នែកសិទ្ធិទទួលបានលំនៅឋានសមរម្យ ដែលត្រូវបានគេទទួលស្គាល់។
- ផ្តល់លំនៅឋានសមរម្យនៅលើទីតាំងលំនៅឋានថ្មីដែលបានរាយឈ្មោះនៅក្នុងរបាយការណ៍នេះ។
- សងបំណុលទាំងអស់ដែលបានកើតឡើងដោយសារការខកខានក្នុងការផ្តល់លំនៅឋានសមរម្យ នៅលើទីតាំងលំនៅឋានថ្មី។
- ធ្វើការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីធានាថា ប្រព័ន្ធការពារ ដែលជួយការពារអ្នកខ្ចីប្រាក់ ត្រូវបានបង្កើតឡើង និងកំណត់អត្តសញ្ញាណប្រជាពលរដ្ឋដែលប្រឈមនឹងអលទ្ធភាពសងបំណុល ដោយសារការឱ្យខ្ចីប្រាក់បែបកេងប្រវ័ញ្ច និងការពារពួកគេពីគ្រោះថ្នាក់ ដែលបង្កឡើងដោយប្រាក់កម្ចីបែបកេងប្រវ័ញ្ចនេះ។






(+855) 023 431 555

sttcambodia

https://teangtnaut.org/